## សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ
## និង វិទ្យាសាស្ត្រសេដ្ឋកិច្ច

## សារណាបញ្ចប់ការសិក្សា

# ឥទ្ធិពលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម
# លើកំណើនសេដ្ឋកិច្ចកម្ពុជា

ស្រាវជ្រាវពីថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៧ ដល់ថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៧


តាក់តែងឡើងដោយ

និស្សិតឈ្មោះ **គង់ រ៉ាណូ**

**សុខុម បញ្ញាវុធ**

សាស្ត្រាចារ្យណែនាំ

បណ្ឌិត **ច៉ាន់ ស៊ុនដេត**


ថ្នាក់បរិញ្ញាបត្រ វិទ្យាសាស្ត្រសេដ្ឋកិច្ច

ជំនាញ សេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ១៦

ឆ្នាំចូលសិក្សា ២០១៣

ឆ្នាំសរសេរសារណា ២០១៧

# សេចក្តីថ្លែងអំណរគុណ

យើងខ្ញុំ **គង់ រ៉ាណា** និង **សុខុម បញ្ញាវុធ** ជានិស្សិតជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ ជំនាន់ទី ១៧ នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច សូមសម្តែងនូវការដឹងគុណដល់ **លោកឪពុក អ្នកម្តាយ** ដែលបានផ្តល់កំណើត ចិញ្ចឹមបីបាច់ អប់រំប្រៀនប្រដៅរូបកូនប្រកបដោយព្រហ្មវិហាធម៌ និងជាពិសេស លោកទាំងពីរបានផ្តល់ឱកាសឲ្យរូបកូនទទួលបានការសិក្សារៀនសូត្រ និងទទួលបានចំណេះដឹងមកទល់ពេលនេះ ។

យើងខ្ញុំ ក៏សូមថ្លែងអំណរគុណដល់ **លោកសាស្ត្រាចារ្យបណ្ឌិត ខ៉ាន់ ស៊ុនដេត** ដែលបានបង្ហាត់បង្រៀន តម្រង់ទិស និងផ្តល់ការណែនាំល្អៗជាច្រើនដល់ពួកយើងខ្ញុំ ដែលធ្វើឲ្យសារណាបញ្ចប់ការសិក្សានេះបានទទួលលទ្ធផលជាផ្លែផ្កាល្អប្រសើរ។

ជាចុងក្រោយ យើងខ្ញុំសូមសម្តែងនូវការដឹងគុណចំពោះ លោក លោកស្រី សាស្ត្រាចារ្យទាំងអស់ដែលបានបង្ហាត់បង្រៀន ផ្តល់នូវមូលដ្ឋានចំណេះដឹងដល់យើងខ្ញុំ សម្រាប់ប្រើប្រាស់ក្នុងការចងក្រងសារណាបញ្ចប់ការសិក្សានេះឡើង និង ក៏សូមថ្លែងអំណរគុណដល់ថ្នាក់ដឹកនាំទាំងអស់នៃសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច ដែលបានបង្កលក្ខណៈងាយស្រួលដល់ការសិក្សា និងការស្រាវជ្រាវឯកសារនេះផងដែរ។

# អារម្ភកថា

បន្ទាប់ពីបានសិក្សាលើមុខជំនាញសេដ្ឋកិច្ចអភិវឌ្ឍន៍ នៅសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច អស់រយៈពេលជិត ៤ឆ្នាំមក យើងខ្ញុំទទួលបាននូវពុទ្ធិជាច្រើននៅលើមុខជំនាញនេះ និងយល់ដឹងនូវវិធីសាស្ត្រនានា ដើម្បីជម្រុញឲ្យមានការអភិវឌ្ឍន៍ប្រកបដោយនិរន្តភាពសម្រាប់ប្រទេសកម្ពុជា និងសម្រាប់ពិភពលោកទាំងមូល។ ដោយឡែក ដើម្បីបំពេញទៅតាមលក្ខខ័ណ្ឌក្នុងការបញ្ចប់ការសិក្សាថ្នាក់បរិញ្ញាបត្រ និងជាការពង្រីកកម្រិតយល់ដឹងបន្ថែម ពួកយើងខ្ញុំបានរៀបចំឯកសារស្រាវជ្រាវមួយនេះឡើង ដែលមានចំណងជើងថា «**ឥទ្ធិពលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម លើកំណើនសេដ្ឋកិច្ចកម្ពុជា**»។

ការជ្រើសរើសប្រធានបទនេះឡើង ដោយសារតែយើងយល់ថា ពាណិជ្ជកម្ម គឺជាកត្តាដ៏សំខាន់ក្នុងការជម្រុញកំណើនសេដ្ឋកិច្ចរយៈពេលវែង របស់ប្រទេសជាតិនីមួយៗនៅក្នុងពិភពលោក។ យ៉ាងណាមិញ ការកែសម្រួល ឬដកចេញនូវរបាំងពាណិជ្ជកម្មអាចបង្កជាផលល្អ ឬផលអាក្រក់ដល់ប្រទេសដែលជាអ្នកអនុវត្ត។ ប្រការនេះ ទាមទារឲ្យមានការវិភាគយ៉ាងម៉ត់ចត់ ទៅលើទំនាក់ទំនងទាំងឡាយក្នុងវិស័យពាណិជ្ជកម្ម មុននឹងឈានដល់ការកំនត់គោលនយោបាយ ។

យើងខ្ញុំសង្ឃឹមថា ឯកសារសារណានេះ នឹងក្លាយជាប្រភពចម្បងមួយសម្រាប់និស្សិតជំនាន់ក្រោយ ទុកជាឯកសារពិគ្រោះលើកិច្ចការស្រាវជ្រាវនានា និងជាពិសេស សម្រាប់ប្អូនៗដែលចង់ធ្វើការស្រាវជ្រាវបន្តលើវិស័យពាណិជ្ជកម្មរបស់កម្ពុជា ។

ជាចុងក្រោយ អាស្រ័យដោយការយល់ដឹងនៅមានកម្រិត ការខ្វះខាតបទពិសោធន៍ក្នុងការអនុវត្តជាក់ស្តែង រួមនឹងភាពពុំសូវសម្បូរបែបនៃឯកសារពិគ្រោះ យើងខ្ញុំជឿជាក់ថាប្រាកដជាមានកំហុសឆ្គង និងចំណុចខ្វះខាតជាក់ជាមិនខាន។ ដូចនេះ យើងខ្ញុំរីករាយ ស្វាគមន៍រាល់មតិរិះគន់ ដើម្បីស្តាបនាពីសំណាក់លោកគ្រូ អ្នកគ្រូ សាស្ត្រាចារ្យ លោក លោកស្រី និងសិស្ស និស្សិត ដើម្បីធ្វើឲ្យសារណាបញ្ចប់ការសិក្សានេះកាន់តែល្អប្រសើរជាងមុន។

# មាតិកា


បញ្ជីអក្សរកាត់ ..... iii

បញ្ជីតារាង ..... iv

បញ្ជីក្រាហ្វិក ..... v

បញ្ជីឧបសម្ព័ន្ធ ..... vi


## សេចក្ដីផ្ដើម


១. លំនាំ និងចំណូលបញ្ហា ..... ១

២. ចំណោទបញ្ហានៃការស្រាវជ្រាវ ..... ១

៣. គោលបំណងនៃការស្រាវជ្រាវ ..... ២

៤. សារៈសំខាន់នៃការស្រាវជ្រាវ ..... ២

៥. ទំហំ និងដែនកំណត់ ..... ៣

៦. វិធីសាស្ត្រស្រាវជ្រាវ ..... ៣

៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ ..... ៤


## ជំពូកទី ១ រំលឹកទ្រឹស្ដី


១.១ និយមន័យសេរីភាវូបនីយកម្មពាណិជ្ជកម្ម ..... ៥

១.២ ទ្រឹស្ដីពាណិជ្ជកម្មអន្តរជាតិ ..... ៦

១.២.១ ទ្រឹស្ដីពាណិជ្ជកម្មនិយម ..... ៦

១.២.២ ទ្រឹស្ដីពាណិជ្ជកម្មបែបក្លាសិក ..... ៦

១.២.៣ ទ្រឹស្ដីពាណិជ្ជកម្មបែបក្លាសិកថ្មី ..... ៨

១.៣ ប្រភេទនៃរបាំងពាណិជ្ជកម្ម ..... ៩

១.៣.១ របាំងពន្ធគយ ..... ៩

១.៣.២ របាំងមិនមែនពន្ធគយ ..... ១០

១.៤ អង្គការពាណិជ្ជកម្មពិភពលោក ..... ១១

១.៤.១ ប្រវត្តិនៃការកកើតអង្គការពាណិជ្ជកម្មពិភពលោក ..... ១១

១.៤.២ លក្ខខ័ណ្ឌនៃការចូលជាសមាជិក WTO ..... ១២

១.៤.៣ គោលបំណងនៃអង្គការពាណិជ្ជកម្មពិភពលោក ..... ១៣

## ជំពូកទី ២ សេរីភាវូបនីយកម្មពាណិជ្ជកម្មនៅកម្ពុជា


២.១ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា.................................................. ១៥
២.១.១ ស្ថានភាពនៃវិស័យពាណិជ្ជកម្ម.................................................. ១៥
២.១.២ ការបើកចំហនៃវិស័យពាណិជ្ជកម្មរបស់កម្ពុជា .................................................. ១៩
២.១.៣ ការវិនិយោគផ្ទាល់ពីបរទេស.................................................. ២១
២.២ សមាហរណកម្មសេដ្ឋកិច្ច.................................................. ២២
២.២.១ អង្គការពាណិជ្ជកម្មពិភពលោក ..................................................២៣
២.២.២ សហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ .................................................. ២៤
២.៣ សេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា ..................................................២៧
២.៣.១ ការកែសម្រួលរបាំងពន្ធគយ ..................................................២៧
២.៣.២ ការកែសម្រួលរបាំងពាណិជ្ជកម្មមិនមែនពន្ធ ..................................................៣០
២.៣.៣ ជំនួយសម្រាប់ពាណិជ្ជកម្ម ..................................................៣១
២.៤ គោលនយោបាយជាតិលើវិស័យពាណិជ្ជកម្ម..................................................៣៣
២.៤.១ យុទ្ធសាស្ត្រចតុកោណ.................................................. ៣៣
២.៤.២ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា..................................................៣៤
២.៤.៣ អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្មកម្ពុជា..................................................៣៥
២.៤.៤ ផែនការជាតិរយៈពេលមធ្យមសម្រាប់អនុវត្ត Trade SWAp............................ ៣៧


## ជំពូកទី ៣ ការវិភាគទិន្នន័យ


៣.១ ការកំណត់អថេរ និងគំរូវិភាគ..................................................៣៨
៣.២ ការពន្យល់អត្ថន័យនៃអថេរវិភាគ..................................................៣៩
៣.៣ ការបង្ហាញទិន្នន័យ .................................................. ៤០
៣.៤ ការបកស្រាយទិន្នន័យ.................................................. ៤១


## សេចក្តីសន្និដ្ឋាន និងអនុសាសន៍


១. សេចក្តីសន្និដ្ឋាន..................................................៤៣
២. អនុសាសន៍ .................................................. ៤៥
**ឯកសារពិគ្រោះ**
**ឧបសម្ព័ន្ធ**

# បញ្ជីអក្សរកាត់

| | |
|---|---|
| ADB | Asian Development Bank (ធនាគារអភិវឌ្ឍន៍អាស៊ី) |
| AfT | Aids for Trade (ជំនួយសម្រាប់ពាណិជ្ជកម្ម) |
| AFTA | ASEAN Free Trade Agreement (កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីអាស៊ាន) |
| ATIGA | ASEAN Trade in Goods Agreement (កិច្ចព្រមព្រៀងស្តីពីពាណិជ្ជកម្មទំនិញអាស៊ាន) |
| CTIS | Cambodia's Trade Integration Strategies (យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា) |
| FDI | Foreign Direct Investment (ការវិនិយោគផ្ទាល់ពីបរទេស) |
| FTA | Free Trade Agreement (កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី) |
| GEL | General Exception List (បញ្ជីអនុគ្រោះទូទៅ) |
| HSL | Higher Sensitive (បញ្ជីវេទយិតភាពខ្ពស់) |
| IL | Inclusive List (បញ្ជីដាក់បញ្ចូល) |
| MFN | Most Favorable Nation (ប្រទេសដែលទទួលបានការអនុគ្រោះ) |
| MTP | Medium Term Plan (ផែនការជាតិរយៈពេលមធ្យម) |
| NTMs | Non-Tariff Measures (វិធានការមិនមែនពន្ធគយ) |
| ODA | Official Development Aids (ជំនួយផ្លូវការសម្រាប់ការអភិវឌ្ឍន៍) |
| RGC | Royal Government of Cambodia (រាជរដ្ឋាភិបាលកម្ពុជា) |
| SL | Sensitive List (បញ្ជីវេទយិតភាព) |
| SPS | Sanitary and Phytosanitary (វិធានការអនាម័យ និងភូតគាមអនាម័យ) |
| TBT | Technical Barrier to Trade (របាំងបច្ចេកទេសពាណិជ្ជកម្ម) |
| TEL | Temporary Exception List (បញ្ជីអនុគ្រោះបណ្តោះអាសន្ន) |
| Trade SWAp | Trade Sector-Wide Approach (អភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម) |
| WTO | World Trade Organization (អង្គការពាណិជ្ជកម្មពិភពលោក) |

## បញ្ជីតារាង


តារាងទី ២.១ ៖ ដៃគូ និងមុខទំនិញនាំចេញរបស់កម្ពុជាឆ្នាំ ២០១៥ ..................................... ១៧

តារាងទី ២.២ ៖ ដៃគូ និងមុខទំនិញនាំចូលរបស់កម្ពុជាឆ្នាំ ២០១៥....................................... ១៨

តារាងទី ២.៣ ៖ ទឹកប្រាក់វិនិយោគផ្ទាល់ពីបរទេសទៅតាមប្រទេសនីមួយៗ .......................... ២២

តារាងទី ២.៤ ៖ វិសាលភាពនៃទំនិញតាមប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន.............. ២៤

តារាងទី ២.៥ ៖ ប្រភេទពន្ធ និងអាករសម្រួលដោយគយ ឆ្នាំ ២០១៥.................................... ២៩

តារាងទី ២.៥ ៖ ពន្ធគយសង្ខេបរបស់កម្ពុជា ឆ្នាំ ២០០៩ ..................................................... ២៩

តារាងទី ២.៦ ៖ ប្រភេទរបាំងមិនមែនពន្ធគយដែលប្រើប្រាស់នៅកម្ពុជា .............................. ៣១

តារាងទី ២.៧៖ អភិក្រមគ្របដណ្ដប់វិស័យពាណិជ្ជកម្ម ...................................................... ៣៧

តារាងទី ៣.១៖ ទិន្នន័យសម្រាប់ធ្វើការវិភាគ ...................................................................... ៤០

តារាងទី ៣.២៖ តារាងទំនាក់ទំនង (ANOVA).................................................................... ៤២

# បញ្ជីក្រាហ្វិក

ក្រាហ្វិកទី ១.១ ៖ គំនូសបំព្រួញអំពីនិន្នាការក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ ............................ ៥
ក្រាហ្វិកទី ២.១ ៖ កំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ ២០០២ ដល់ ២០១៦ .................................. ១៤
ក្រាហ្វិកទី ២.២ ៖ ការចូលរួមនៃវិស័យចម្បងទាំងបីនៅក្នុងសេដ្ឋកិច្ចកម្ពុជា........................... ១៥
ក្រាហ្វិកទី ២.៣ ៖ ស្ថិតិការនាំចេញ នាំចូល និងទំហំពាណិជ្ជកម្មរបស់កម្ពុជា.......................... ១៦
ក្រាហ្វិកទី ២.៤ ៖ ជញ្ជីងពាណិជ្ជកម្មកម្ពុជា ........................................................................ ១៩
ក្រាហ្វិកទី ២.៥ ៖ Cambodia's Enabling Trade Index ២០១៥ ............................................ ២០
ក្រាហ្វិកទី ២.៦ ៖ កំណើននៃការវិនិយោគផ្ទាល់ពីបរទេស................................................... ២១
ក្រាហ្វិកទី ២.៧ ៖ ជំនួយសម្រាប់ពាណិជ្ជកម្មមកកាន់កម្ពុជា ឆ្នាំ ២០០៨ និង ២០១៣ ............ ៣៣
ក្រាហ្វិកទី ២.៨ ៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣................................................ ៣៤

# បញ្ជីឧបសម្ព័ន្ធ

ឧបសម្ព័ន្ធទី ១ ៖ ទិន្នន័យពាណិជ្ជកម្មកម្ពុជាឆ្នាំ ២០១៥
ឧបសម្ព័ន្ធទី ២ ៖ Cambodia's Enabling Trade Index 2015
ឧបសម្ព័ន្ធទី ៣ ៖ ប្រពន្ធ័អនុគ្រោះពន្ធគយផ្អែកលើកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា
ឧបសម្ព័ន្ធទី ៤ ៖ ប្រកាសស្ដីពីការកែសម្រួលអត្រាពន្ធគយលើទំនិញមួយចំនួន
ឧបសម្ព័ន្ធទី ៥ ៖ ជំនួយសម្រាប់ពាណិជ្ជកម្មមកកាន់កម្ពុជា

# សេចក្តីផ្តើម

## ១. លំនាំ និងចំណោទបញ្ហា

ការធ្វើសមាហរណកម្មសេដ្ឋកិច្ចអន្តរជាតិ ចាប់ផ្តើមទទួលភាពការរីកចម្រើនយ៉ាងឆាប់រហ័សនៅពាក់កណ្តាលទសវត្សទី៨០។ ក្នុងរវាងឆ្នាំ១៩៨៥ ដល់ ២០០០ ផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំ របស់ពិភពលោកបានកើនឡើងជាមធ្យមប្រមាណ ៣.៨%។ នេះជាលទ្ធផល បានមកពីចំណែកនៃការនាំចេញ និងការវិនិយោគដោយផ្ទាល់ពីបរទេសនៅតាមបណ្តាប្រទេសនានា។[1]

ងាកមកមើលបរិបទនៃប្រទេសកម្ពុជាយើងវិញ នៅដើមទសវត្សទី៩០ កម្ពុជាបានចាប់ផ្តើមធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងសមាហរណកម្មសេដ្ឋកិច្ច។ គោលដៅចម្បងបំផុត នៃនយោបាយសេដ្ឋកិច្ចក្រៅប្រទេសរបស់កម្ពុជា គឺការពង្រីក និងពង្រឹងនូវទំនាក់ទំនងសេដ្ឋកិច្ច និងកិច្ចសហប្រតិបត្តិការអន្តរជាតិ តាមរយៈការធ្វើសមាហរណកម្មសេដ្ឋកិច្ចកម្ពុជា ចូលទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ គោលដៅនេះត្រូវបានកំណត់ឡើង គឺដើម្បីប្រើប្រាស់គុណប្រយោជន៍នៃការបែងចែកកម្លាំងពលកម្មអន្តរជាតិ ពោលគឺដើម្បីជម្រុញការអភិវឌ្ឍសេដ្ឋកិច្ច និងលើកកម្ពស់សុខមាលភាពរបស់ប្រជាជន ។

សេរីភាវូបនីយកម្មពាណិជ្ជកម្ម ជាដំណើរការមួយយ៉ាងសំខាន់ សម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍ដូចប្រទេសកម្ពុជា ក្នុងការជម្រុញកំណើនសេដ្ឋកិច្ច។ យោងទៅតាមផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិកម្ពុជា២០១៤-២០១៨ រាជរដ្ឋាភិបាលកម្ពុជាចាត់ទុកថាការធ្វើពាណិជ្ជកម្មជាធនធានមួយដ៏ចម្បងសម្រាប់កំណើនសេដ្ឋកិច្ច និងការកាត់បន្ថយភាពក្រីក្រ។ ដូច្នេះ រាជរដ្ឋាភិបាលខិតខំបន្តបោះជំហានបន្ថែមទៀតនៅលើមាគ៌ានៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម ក្នុងគោលបំណងជម្រុញ និងសម្រួលចលនាដោយសេរីនៃទំនិញ និងសេវាកម្មរវាងប្រទេសកម្ពុជា និងប្រទេសជាដៃគូពាណិជ្ជកម្ម។

## ២. ចំណោទបញ្ហានៃការស្រាវជ្រាវ

បទពិសោធន៍នៅក្នុងប្រទេសជាច្រើនលើសកលលោក បានឆ្លុះបញ្ចាំងពីជោគជ័យដ៏សម្បើមនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម។ ដោយឡែក នៅមានមតិមួយចំនួន ដែលបង្ហាញពីការព្រួយបារម្ភ

[1] Faini. R. Trade Liberalization in a Globalizing World [សេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងសាកលភាវូបនីយកម្មពិភពលោក] Discussion Paper 1406. (The Institute for the Study of Labor, 2004)

ចំពោះការអនុវត្តគោលនយោបាយពាណិជ្ជកម្មបែបនេះ ដោយហេតុថា ប្រទេសកំពុងអភិវឌ្ឍន៍អាចនឹងមិនទទួលបានផលប្រយោជន៍ច្រើនពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម ឬធ្ងន់ធ្ងរជាងនេះ គឺប្រឈមមុខ នឹងការខាតបង់សេដ្ឋកិច្ច។

អាស្រ័យដូចនេះ វាពិតជាមានសារៈសំខាន់សម្រាប់អ្នកសិក្សាស្រាវជ្រាវទាំងឡាយ និងអ្នកធ្វើគោលនយោបាយ ក្នុងការស្វែងយល់ឲ្យកាន់តែច្បាស់ពីទំនោរ ស្ថានភាពបច្ចុប្បន្ន និងទំនាក់ទំនងរវាងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងកំណើនសេដ្ឋកិច្ចក្នុងលក្ខខណ្ឌប្រទេសកម្ពុជា។ តាមរយៈបញ្ហាខាងលើ ការសិក្សានេះនឹងផ្តោតសំខាន់លើបញ្ហាចោទមួយគឺ ៖

តើសេរីភាវូបនីយកម្មពាណិជ្ជកម្ម មានឥទ្ធិពលបែបណាមកលើកំណើនសេដ្ឋកិច្ចកម្ពុជា?

## ៣. គោលបំណងនៃការស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវលើប្រធានបទ «**ឥទ្ធិពលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម លើកំណើនសេដ្ឋកិច្ចកម្ពុជា**» មានគោលបំណងដូចតទៅ ៖

- បង្ហាញពីស្ថានភាពនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅប្រទេសកម្ពុជាកន្លងមក
- បង្ហាញពីឥទ្ធិពលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម លើកំណើនសេដ្ឋកិច្ចកម្ពុជា

## ៤. សារៈសំខាន់នៃការស្រាវជ្រាវ

ចាប់តាំងពីប្រទេសកម្ពុជា បានប្រកាន់យកប្រព័ន្ធសេដ្ឋកិច្ចបែបទីផ្សារសេរី នាឆ្នាំ១៩៩៣ មក កម្ពុជាទទួលបានផលប្រយោជន៍យ៉ាងសន្ធឹកសន្ធាប់ពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែលជាកត្តាមួយចូលរួមចំណែកជម្រុញនូវកំណើនសេដ្ឋកិច្ចរហូតដល់សព្វថ្ងៃ។ យ៉ាងណាមិញ គេមើលឃើញថាកម្ពុជាក៏រងផលប៉ះពាល់មួយចំនួនផងដែរ ពីការអនុវត្តគោលនយោបាយពាណិជ្ជកម្មនេះ។ ទន្ទឹមនឹងនេះ ក្នុងឆ្នាំ២០១៥ ប្រទេសកម្ពុជាបានធ្វើ សមាហរណកម្មទៅក្នុងសមាគមន៍សេដ្ឋកិច្ចអាស៊ាន ដែលធ្វើឲ្យលទ្ធភាពនៃការធ្វើពាណិជ្ជកម្មដោយសេរី បានក្លាយជាប្រធានបទមួយដែលអ្នកសិក្សាស្រាវជ្រាវលើកមកពិភាក្សាយ៉ាងផុសផុល។

ផ្អែកតាមការរៀបរាប់ខាងលើ ការចងក្រងនូវឯកសារនេះឡើង អាចផ្តល់ជាគុណប្រយោជន៍មួយចំនួនដូចជា៖

- ចែករំលែកនូវចំណេះដឹងពាក់ព័ន្ធនឹងគោលនយោបាយពាណិជ្ជកម្ម និង ការអនុវត្តនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅកម្ពុជា

- ផ្តល់ជាទស្សនៈទាន និងអនុសាសន៍មួយចំនួន សម្រាប់ពិចារណា ក្នុងការកំណត់គោលនយោបាយពាណិជ្ជកម្មអន្តរជាតិរបស់កម្ពុជា
- ផ្តល់ជាឯកសារជំនួយ សម្រាប់ការស្រាវជ្រាវក្រោយៗ និងជាការបំពេញលើការស្រាវជ្រាវកន្លងមក ដែលទាក់ទងទៅនឹងសេរីភាវូបនីយកម្មពាណិជ្ជកម្មរបស់ប្រទេសកម្ពុជា។

## ៥. ទំហំ និងដែនកំណត់

ទំហំនៃការសិក្សា គឺផ្តោតសំខាន់លើឥទ្ធិពលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្ម មកលើកំណើនសេដ្ឋកិច្ចនៅកម្ពុជា ក្នុងរយៈពេល ២២ឆ្នាំចុងក្រោយ ពោលគឺ ចាប់ពីឆ្នាំ ១៩៩៤ ដល់ឆ្នាំ ២០១៥។ ចំពោះដែនកំណត់នៃការសិក្សា យើងឃើញថាទិន្នន័យ និងព័ត៌មានទាំងឡាយដែលបានដកស្រង់នៅមានកម្រិត និងមានភាពខ្វះខាត ដែលអាចជះឥទ្ធិពលមួយចំនួនទៅលើការបកស្រាយទិន្នន័យ ។

## ៦. វិធីសាស្ត្រស្រាវជ្រាវ

ការសិក្សាស្រាវជ្រាវនេះនឹងធ្វើការប្រើប្រាស់នូវវិធីចម្រុះ ពោលគឺគុណវិស័យ (Qualitative Approach) និង បរិមាណវិស័យ (Quantitative Approach) ដើម្បីបកស្រាយចំណោទបញ្ហា និងគោលបំណងនៃការសិក្សា។

ទិន្និន័យដែលប្រើប្រាស់ក្នុងការបកស្រាវជ្រាវ សុទ្ធសឹងតែជាទិន្និន័យទី២ (Secondary Data) ដែលដកស្រង់ចេញពីប្រភពផ្សេងៗគ្នាជាច្រើន។ ក្នុងនោះ សន្ទស្សន៍នៃការអភិវឌ្ឍពិភពលោក (World Development Indicators) ត្រូវបានប្រើប្រាស់ជាទិន្និន័យសម្រាប់ធ្វើការវិភាគ។ ដោយឡែកទិន្និន័យដែលទទួលបានពីប្រភពដូចជា World Economic Forum, Global EDGE, វិទ្យស្ថានស្រាវជ្រាវសេដ្ឋកិច្ចអាស៊ាន, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងផែនការ, ធនគារជាតិ និងប្រភពមួយចំនួនទៀត ត្រូវបានប្រើប្រាស់សម្រាប់ការពិពណ៌នាអំពីការវិវត្តន៍ នៃសេរីភាវូបនីយកម្មពាណិជ្ជកម្មនៅកម្ពុជា ។

ការវិភាគត្រូវបានធ្វើឡើងតាមការកំណត់សមីការទំនាក់ទំនង (Log-linear regression) នៃកំណើនសេដ្ឋកិច្ចជាមួយនឹងអថេរពន្យល់ចំនួនបី ដែលមានដូចជា ការបើកចំហនៃពាណិជ្ជកម្ម (Trade Openness) ការវិនិយោគផ្ទាល់ពីបរទេស (FDI) និងការចំណាយមូលធនដុល (Gross Capital Formation) ។ ការវិភាគនេះ ត្រូវបានរៀបចំឡើង តាមរយៈការប្រើប្រាស់កម្មវិធី SPSS ។

## ៧. រចនាសម្ព័ន្ធនៃការស្រាវជ្រាវ

អត្ថបទសារណាបញ្ចប់ការសិក្សាក្រោមប្រធានបទ «**ឥទ្ធិពលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មលើកំណើនសេដ្ឋកិច្ចកម្ពុជា**» ត្រូវបានបែងចែកជាប្រាំផ្នែកធំៗ ៖

**សេចក្តីផ្តើម**

ជាផ្នែកចាប់ផ្តើមដែលបង្ហាញពីលំនាំបញ្ហា ចំណោទបញ្ហា គោលបំណងនៃការស្រាវជ្រាវ សារៈសំខាន់នៃការស្រាវជ្រាវ ទំហំ និងដែនកំណត់នៃការស្រាវជ្រាវ និងវិធីសាស្ត្រស្រាវជ្រាវ។

**ជំពូកទី ១ ៖ រំលឹកទ្រឹស្តី**

ផ្នែកនេះពន្យល់អំពីនិយមន័យនៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបង្ហាញពីទ្រឹស្តីសំខាន់ៗទាក់ទងទៅនឹងពាណិជ្ជកម្មអន្តរជាតិ។

**ជំពូកទី ២ ៖ សេរីភាវូបនីយកម្មពាណិជ្ជកម្មនៅកម្ពុជា**

ផ្នែកនេះបកស្រាយទៅលើស្ថានភាពទូទៅនៃសេដ្ឋកិច្ច និងពាណិជ្ជកម្មរបស់កម្ពុជា។ ក្នុងនោះ រួមបញ្ចូលទាំងការវិវត្តន៍នៃការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងគោលនយោបាយជាតិនានាលើវិស័យពាណិជ្ជកម្ម ដែលកម្ពុជាបានអនុវត្តក្នុងពេលកន្លងមក។

**ជំពូកទី ៣ ៖ ការវិភាគទិន្នន័យ**

ផ្នែកនេះធ្វើការបង្ហាញនូវទិន្នន័យ និងការវិភាគលើទំនាក់ទំនង រវាងសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងកំណើនសេដ្ឋកិច្ចកម្ពុជា ដោយភ្ជាប់ជាមួយនឹងការពិភាក្សា និងការបកស្រាយទៅលើលទ្ធផល ដែលទទួលបាន។

**សេចក្តីសន្និដ្ឋាន និងអនុសាសន៍**

ផ្នែកនេះធ្វើការប្រមូលបញ្ចូលនូវទិន្និន័យ និងព័ត៌មានដែលបានរៀបរាប់ក្នុងជំពូកទាំង ៣ ខាងលើ ដើម្បីទាញយកការសន្និដ្ឋានមួយ ឆ្លើយតបទៅនឹងចំណោទបញ្ហានៃការស្រាវជ្រាវ។ ជាមួយគ្នានេះ អនុសាសន៍មួយចំនួនត្រូវបានដាក់ភ្ជាប់ជាមួយគ្នាផងដែរ។

# ជំពូកទី១
# រំលឹកទ្រឹស្តី

## ១.១ និយមន័យសេរីភាវូបនីយកម្មពាណិជ្ជកម្ម

សេរីភាវូបនីយកម្មពាណិជ្ជកម្ម (Trade Liberalization) ត្រូវបានគេឲ្យនិយមន័យថា គឺជាការដកចេញ ឬកាត់បន្ថយការដាក់កំហិតលើលំហូរដោយសេរីនៃទំនិញពីប្រទេសមួយ ទៅប្រទេសមួយ។ វារួមបញ្ចូលទាំងការដកចេញ ឬកាត់បន្ថយរបាំងពន្ធគយ និងរបាំងមិនមែនពន្ធគយ (Githanga, 2015)។

ម្យ៉ាងវិញទៀតពាក្យថា សេរីភាវូបនីយកម្មពាណិជ្ជកម្ម គឺជាដំណើរឈានទៅរកការធ្វើពាណិជ្ជកម្មសេរី (Free Trade) ពោលគឺតាមរយៈការកាត់បន្ថយរបាំងពន្ធគយ និងរបាំងផ្សេងៗទៀត ដែលត្រូវបានគេជឿថាជាកម្លាំងជម្រុញសាកលភាវូបនីយកម្ម ។ ការកើនឡើងយ៉ាងឆាប់រហ័សនៃចលនាលំហូរទំនិញ និងសេវាកម្មត្រូវបានគេមើលឃើញថាជាកត្តា ជម្រុញឲ្យមានកំណើនការធ្វើសមាហរណកម្មសេដ្ឋកិច្ចជាសកលក្នុងរយៈពេលទសវត្សរ៍ចុងក្រោយនេះ (Lee, 2005)។

**ក្រាហ្វិកទី ១.១៖ គំនូសបំព្រួញអំពីនិន្នាការក្នុងការធ្វើពាណិជ្ជកម្មអន្តរជាតិ**




**ប្រភព:** *ឡុង ម៉ាមីឌី, ២០១៣*

និន្នាការផ្ទុយទៅនឹង សេរីភាវូបនីយកម្មពាណិជ្ជកម្ម គឺនយោបាយគាំពារនិយម (Protectionism) ដែលជាគោលនយោបាយសេដ្ឋកិច្ចមួយរឹតបន្តឹងការនាំចេញ-នាំចូល នៃទំនិញ និងសេវាកម្មតាមរយៈការដាក់របាំងការពារទីផ្សារ ដែលមានដូចជា ពន្ធគយ និងរបាំងមិនមែនពន្ធគយ ។

និន្នាការគាំពារនិយមអាចនាំមកនូវទម្រង់សេដ្ឋកិច្ចមួយដែលហៅថា សេដ្ឋកិច្ចម្ចាស់ការ ឬសេដ្ឋកិច្ចបិទ (Autarky) ដែលមិនអនុញ្ញាតឲ្យមានការនាំចេញ-នាំចូល នៃទំនិញ ឬសេវាកម្ម។[2]

[2] ឡុង ម៉ាមីឌី, *សេដ្ឋកិច្ចអន្តរជាតិ*, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាប័ត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៣) ។

ទម្រង់សេដ្ឋកិច្ចបិទនេះ អាចជាការ បិទទាំងស្រុងនៃលំហូរទំនិញ និងសេវាកម្ម គ្រប់ប្រភេទ ឬការបិទតែប្រភេទជាក់លាក់មួយចំនួន។

## ១.២. ទ្រឹស្តីពាណិជ្ជកម្មអន្តរជាតិ (International Trade Theory)

### ១.២.១ ទ្រឹស្តីពាណិជ្ជកម្មនិយម (Mercantilism)

ដោយសារតែដំណើរការមិនល្អនៃរបបសក្តិភូមិនិយម របបនេះត្រូវបានដួលរលំក្នុងកំឡុងប្រហែលជាសតវត្សទី១៥ ឬ ១៦។ ក្រោយពីការដួលរលំនៃមធ្យោបាយចាស់ដែលមានលក្ខណៈជាសង្គម-សេដ្ឋកិច្ចប្រពៃណីដែលបានបន្តមកជាយូរ គេបានសង្កេតឃើញមានការកើតឡើងនូវរបៀបថ្មីមួយទៀតគឺ ពាណិជ្ជកម្មនិយម ។ ពាណិជ្ជកម្មនិយម គឺជាប្រព័ន្ធសេដ្ឋកិច្ចមួយដែលអនុវត្តដោយប្រទេសអង់គ្លេស និងបណ្តាប្រទេសពាណិជ្ជកម្មសំខាន់ៗដទៃទៀត ជាពិសេសបណ្តាប្រទេសនៅអឺរ៉ុបចាប់តាំងពីសតវត្សរ៍ទី១៥ រហូតដល់ចុងសតវត្សរ៍ទី១៧។ ស្ថិតនៅក្រោមប្រព័ន្ធសេដ្ឋកិច្ចនេះ រដ្ឋាភិបាលរបស់ប្រទេសនីមួយៗបានកំណត់ និងដាក់បទប្បញ្ញត្តិយ៉ាងតឹងរឹងទៅលើកិច្ចការសេដ្ឋកិច្ច ដើម្បីបង្កើនទ្រព្យសម្បត្តិក្នុងរតនាគាររបស់ខ្លួន ជាពិសេសដោយធានាថាការនាំចេញត្រូវតែលើស ឬច្រើនជាងការនាំចូល។

ដោយយោងទៅលើពួកអ្នកពាណិជ្ជកម្មនិយមនេះ ប្រជាជាតិមួយដែលមិនមាន «រ៉ែមាស» និង «រ៉ែប្រាក់» ត្រូវតែពឹងផ្អែកលើពាណិជ្ជកម្មអន្តរជាតិដើម្បីក្លាយខ្លួនទៅជាប្រទេសអ្នកមាន។ ពួកអ្នកពាណិជ្ជកម្មនិយម បានទាមទារឲ្យមានភាពលើសនៃការនាំចេញច្រើនជាងការនាំចូល (Trade Surplus) ដែលស្ថានភាពបែបនេះពួកគេឲ្យឈ្មោះថា ជញ្ជីងពាណិជ្ជកម្មល្អ (Favorable balance of trade)។ ដើម្បីរក្សាតុល្យភាពជញ្ជីងពាណិជ្ជកម្ម បណ្តារដ្ឋាភិបាលដែលមានទំនោរទៅលើពាណិជ្ជកម្ម វិស័យនិយមបានអនុម័តតារាងពន្ធខ្ពស់ និងមានបទប្បញ្ញត្តិតឹងរឹងផ្សេងទៀតទៅលើការនាំចូល។ បណ្តារដ្ឋាភិបាលទាំងនោះ ក៏បានជម្រុញយ៉ាងមុតមាំផងដែរ ក្នុងការលើកស្ទួយឲ្យមានការរីកចម្រើននូវឧស្សាហកម្មក្នុងស្រុក[3]។

### ១.២.២ ទ្រឹស្តីពាណិជ្ជកម្មបែបក្លាសិក (Classical Trade Theory)

#### ក. ទស្សនៈទានឧត្តមភាពដាច់ខាត (Absolute Advantage Theory)

លោក Adam Smith (១៧២៣-១៧៩០) ជាអ្នកទ្រឹស្តីសេដ្ឋកិច្ចនយោបាយក្លាសិកដ៏ល្បីឈ្មោះនៅអង់គ្លេស។ បើតាមលោក Adam Smith ទស្សនៈទាន ឧត្តមភាពដាច់ខាត សំដៅលើ

[3] ស៊ុំ សុចិន្តា, *ប្រវត្តិគំនិតសេដ្ឋកិច្ច*, បោះពុម្ពលើកទី៥, (ភ្នំពេញ៖ សាកលវិទ្យាល័យជាតិគ្រប់គ្រង, ២០១៣), ៦៦-៦៨ ។

សមត្ថភាពរបស់ប្រទេសមួយក្នុងការផលិត ទំនិញ ឬសេវាកម្មបានច្រើនជាង ប្រទេសដទៃដោយប្រើប្រាស់ធនធានដូចគ្នា។ ក្នុងន័យនេះ នៅពេលប្រទេសមួយមានឧត្តមភាពដាច់ខាតក្នុងផលិតកម្មណាមួយ គេត្រូវប្រកាន់យកឯកទេសកម្មលើផលិតកម្មនោះ ដើម្បីផលិតវា និងធ្វើការនាំចេញនោះគេនឹងទទួលបានផលចំណេញ។ នៅក្នុងគំរូនេះ លោក Adam Smith សន្មតថាមានតែប្រទេសពីរ និងផលិតផលពីរ ចំណែកឯពលកម្មជាកត្តាផលិតកម្មតែមួយគត់សម្រាប់ផលិតផល និងអាចផ្លាស់ប្តូរដោយសេរី ពីវិស័យផលិតកម្មមួយទៅផលិតកម្មមួយផ្សេងទៀត។ ក្នុងនោះទីផ្សារមានភាពប្រកួតប្រជែងដោយសេរី និងព័ត៌មានពេញលេញត្រឹមត្រូវ ។

**ខ. ទស្សនៈទានឧត្តមភាពប្រៀបធៀប** ( Comparative Advantage Theory )

ទស្សនៈទាន ឧត្តមភាពប្រៀបធៀប ជាមូលដ្ឋានសំខាន់នៃការសិក្សាវិភាគលើពាណិជ្ជកម្មអន្តរជាតិ ដែលទស្សនៈទាននេះត្រូវបានបង្កើតឡើងដោយលោក David Ricardo (១៧៧២-១៨២៣) ដែលជាសេដ្ឋវិទូជនជាតិអង់គ្លេស។ បើតាមលោក David Ricardo ទស្សនៈទានឧត្តមភាពប្រៀបធៀប (Comparative Advantage) មានន័យថាជាសមត្ថភាពដែលប្រទេសមួយអាចផលិតទំនិញ ឬសេវាកម្មដែលមានតម្លៃឱកាស (Opportunity Cost) ទាបជាងប្រទេសដទៃ។ ក្នុងន័យនេះវាអនុញ្ញាតឲ្យប្រទេសនីមួយៗធ្វើឯកទេសកម្មលើមុខទំនិញ ឬសេវាកម្មដែលខ្លួនមាន Comparative Advantage ហើយធ្វើពាណិជ្ជកម្មអន្តរជាតិដើម្បីដោះដូរទំនិញ ឬ សេវាកម្មដែលខ្លួនត្រូវការ។ នោះប្រទេសនីមួយៗដែលជាដៃគូពាណិជ្ជកម្មជាមួយគ្នា នឹងទទួលបានអត្ថប្រយោជន៍ និងចំណេញពីគ្នាទៅវិញទៅមក[4]។

ក្នុងគំរូ Ricardian Model បានបង្ហាញពីលក្ខណៈប្លែកៗខុសពីគ្នារវាងប្រទេសនីមួយៗ ដែលជាកត្តាជម្រុញឲ្យមានកំណើនការធ្វើពាណិជ្ជកម្ម និង ការទទួលផលប្រយោជន៍ពីការធ្វើពាណិជ្ជកម្ម។ នៅក្នុងគំរូនេះ កម្លាំងពលកម្មជាកត្តាផលិតកម្មតែមួយគត់ ហើយប្រទេសនីមួយៗខុសគ្នាចំពោះតែផលិតភាពនៃកម្លាំងពលកម្ម (The productivity of labor) នៅក្នុងឧស្សាហកម្មផ្សេងគ្នា។[5] ដូច្នេះគោលការណ៍នៃ Comparative Advantage របស់លោក Ricardo បញ្ជាក់យ៉ាងច្បាស់ថាពាណិជ្ជកម្មអន្តរជាតិអាចប្រព្រឹត្តទៅបាន ដោយសារតែភាពខុសគ្នានៃផលិតភាពកម្លាំង

[4] Paul R. Krugman និង Maurice Obstfeld, *International Economics* (6th eds.) [សេដ្ឋកិច្ចអន្តរជាតិ] (MA: Pearson Education, 2003), 34។

[5] Robert J. Carbaugh, *International Economics* (11th eds.) [សេដ្ឋកិច្ចអន្តរជាតិ] (USA: Thomsom Higher Education, 2007). 33។

ពលកម្មរបស់ប្រទេសនីមួយៗ។ ការព្យាករណ៍ជាមូលដ្ឋាននៃគោលការណ៍នេះ គឺប្រទេសនីមួយនៅលើសាកលលោក នឹងទំនងជាធ្វើការនាំចេញរាល់ទំនិញណាដែលមានផលិតភាពនៃកម្លាំងពលកម្មខ្ពស់។

### ១.២.៣ ទ្រឹស្តីពាណិជ្ជកម្មបែបក្លាស៊ិកថ្មី (New Classical Trade Theory)

នៅក្នុងឆ្នាំ១៩១៩ លោក Eli Heckscher ជាសេដ្ឋវិទូជនជាតិស៊ុយអ៊ែត បានបោះពុម្ពផ្សាយអត្ថបទមួយមានចំណងជើងថា «The Effect of Foreign Trade on the Distribution of Income» ដែលប្រែជាភាសាខ្មែរថា «ឥទ្ធិពលនៃពាណិជ្ជកម្មបរទេសលើការបែងចែកប្រាក់ចំណូល»។ ក្នុងអត្ថបទនេះបានបង្ហាញពីចំណុចសំខាន់ៗមួយចំនួនដែលបានក្លាយជា «ទ្រឹស្តីទំនើបនៃពាណិជ្ជកម្មអន្តរជាតិ» នាដើមសតវត្សទី២០។ នៅក្នុងឆ្នាំ១៩៣៣ លោក Bertil Ohlin ដែលជាសិស្សរបស់លោក Eli Heckscher បានបកស្រាយបន្ថែមលើទ្រឹស្តីរបស់ Hecksher ហើយបានបោះពុម្ពផ្សាយនូវសៀវភៅដ៏ល្បីល្បាយមួយរបស់គាត់មានឈ្មោះថា «Interregional and International Trade» (អន្តរតំបន់ និងពាណិជ្ជកម្មអន្តរជាតិ)។ ដូចនេះ ទ្រឹស្តីរបស់លោក Eli Hecksher និងទ្រឹស្តីរបស់ Bertil Ohlin បានបញ្ចូលគ្នាហើយបង្កើតបានជាទ្រឹស្តីមួយហៅថា «**Heckscher-Olin Model**»។ យោងទៅតាមគំរូ Heckscher-Ohlin Model ប្រទេសមួយដែលមានភាពសម្បូរក្នុងការផ្គត់ផ្គង់នូវកត្តាផលិតកម្មនឹងមាន Comparative Advantage ចំពោះទំនិញណាដែលមានប្រពលភាពក្នុងកត្តាផលិតកម្មនោះ (Intensive of Production)។ មានន័យថា បើសិនជាប្រទេសមួយសម្បូរទៅដោយមូលធននឹងមាន Comparative Advantage នៅក្នុងឧស្សាហកម្មដែលប្រើមូលធនច្រើនដូចជាឧស្សាហកម្មចម្រាញ់ប្រេងកាត។ ផ្ទុយទៅវិញប្រទេសមួយសម្បូរទៅដោយកម្លាំងពលកម្មនឹងមាន Comparative Advantage នៅក្នុងឧស្សាហកម្មណាដែលប្រើកម្លាំងពលកម្មច្រើនដូចជាឧស្សាហកម្មកាត់ដេរ[6]។

**ការសន្មតរបស់ទ្រឹស្តី H.O [7]:**

- មានប្រទេសពីរ (ប្រទេសទី១ និងប្រទេសទី២) មានទំនិញពីរប្រភេទ គឺទំនិញ X និងទំនិញY និងមានកត្តាផលិតកម្មពីរគឺពលកម្ម និងមូលធន។

[6] Paul krugman, Robin Wells, Kathryn Graddy, Essential of Economic, [សារៈសំខាន់នៃវិទ្យាសាស្ត្រសេដ្ឋកិច្ច] 3rd Edition, (Worth Publisher, 2013). 579.

[7] ឃឹម ច័ន្ទតារា និង ធូ ស្រីស្រស់, *ការជំរុញការនាំចេញអង្ករកម្ពុជាឆ្នាំ ២០១៥ (សម្ព័ន្ធអ្នកផលិតស្រូវ និងនាំចេញអង្ករកម្ពុជា),* សារណាបញ្ចប់ការសិក្សា, (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៣), ១៣ ។

- ប្រទេសពីរប្រើប្រាស់បច្ចេកទេសដូចគ្នាក្នុងវិស័យផលិតកម្ម។
- ទំនិញ X មានប្រពលភាពខាងពលកម្ម (Labor Intensive) ហើយទំនិញ Y មានប្រពលភាពខាងមូលធន (Capital intensive) ក្នុងប្រទេសទាំងពីរ។
- Constant Return to Scale ក្នុងវិស័យផលិតកម្មនៃទំនិញទាំងពីរក្នុងប្រទេសទាំងពីរ។
- ប្រទេសទាំងពីរមានឯកទេសកម្មមិនពេញលេញដូចគ្នានៅក្នុងវិស័យផលិតកម្ម។
- មានកម្រិតនៃតម្រូវការស្មើគ្នានៅក្នុងប្រទេសទាំងពីរ។
- មានការប្រកួតប្រជែងពេញលេញលើមុខទំនិញទាំងពីរ និងទីផ្សារនៃប្រទេសទាំងពីរ។
- មានការប្រមូលផ្តុំពេញលេញនៃកត្តាផលិតកម្មនៅក្នុងប្រទេសនីមួយៗ ប៉ុន្តែគ្មានការប្រមូលកត្តាផលិតកម្មជាលក្ខណៈអន្តរជាតិទេ។
- គ្មានការចំណាយលើការដឹកជញ្ជូន ពន្ធគយ ឬឧបសគ្គផ្សេងៗដើម្បីឲ្យការដោះដូរពាណិជ្ជកម្ម អន្តរជាតិមានចលនាសម្លូរដោយសេរី។

## ១.៣. ប្រភេទនៃរបាំងពាណិជ្ជកម្ម

### ១.៣.១ របាំងពន្ធគយ

ពន្ធគយគឺជាការយកពន្ធទៅលើទំនិញ ដែលធ្វើពាណិជ្ជកម្មឆ្លងកាត់ព្រំដែននៃប្រទេស ទាំងការនាំចេញ និងការនាំចូល។ ទោះបីជាយ៉ាងណាក៏ដោយ រដ្ឋាភិបាលបានរឹតបន្តឹងពន្ធគយទៅលើ ការនាំចូល ជាជាងការនាំចេញ។

មានហេតុផលយ៉ាងហោចណាស់ ៤ ដែលគួរពិចារណាក្នុងការសម្រេចចិត្តដាក់ពន្ធគយ។ ទី១ ពន្ធគយ ក៏ដូចជាពន្ធដទៃទៀតដែរ វាត្រូវបានគេប្រើជាមធ្យោបាយ បង្អាក់ដល់ការប្រើប្រាស់នូវទំនិញណាមួយ។ ដោយការដាក់ពន្ធគយលើទំនិញនាំចូល ទំនិញនោះនឹងមានតម្លៃខ្ពស់ជាងធម្មតា។ ទី២ ការដាក់ពន្ធគយ គឺដើម្បីចំណូលរដ្ឋាភិបាលតាមរយៈការយកពន្ធគយលើទំនិញនាំចូល ពិសេសសម្រាប់ប្រទេសកំពុងអភិវឌ្ឍន៍។ ទី៣ ការដាក់ពន្ធគយនេះ គឺដើម្បីបង្អាក់ដល់ការនាំចូលដែលជួយសម្រួលដល់ការកាត់បន្ថយឱនភាពជញ្ជីង ពាណិជ្ជកម្ម។ ទី៤ ជាគោលបំណងដ៏សាមញ្ញមួយរបស់ពន្ធគយ គឺជាគោលនយោបាយការពារនិយមដើម្បីការពារសហគ្រាសរោងចក្រក្នុងស្រុកពីការប្រកួតប្រជែងដោយផលិតផលដូចគ្នាមកពីក្រៅប្រទេស។[8]

[8] ហឿន រតនៈ និង គាន ចន្ទ្រាវត្តី, *ឥទ្ធិពលនៃកំណែទម្រង់របាំងពាណិជ្ជកម្មលើការនាំចេញ-នាំចូលរបស់ប្រទេសកម្ពុជា,* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ, (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនិតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ១០

ពន្ធគយត្រូវបានគេបែងចែកជា២ប្រភេទធំៗគឺ

**ពន្ធតាមតម្លៃទំនិញ (Ad Valorem Tariff)៖** ជាការយកកម្រិតពន្ធលើទំនិញនាំចេញ នាំចូល ដោយផ្អែកលើតម្លៃរបស់ទំនិញនោះ ដោយគិតជាភាគរយនៃតម្លៃរបស់ទំនិញ ទោះបីជាទំនិញនោះ មានបរិមាណច្រើន ឬតិចយ៉ាងណាក៏ដោយ។ ឧទាហរណ៍: ការយកពន្ធ ១០% ទៅលើការនាំចូល កុំព្យូទ័រដែលមានតម្លៃ ១,០០០ដុល្លារ គឺត្រូវបង់ពន្ធ ១០០ដុល្លារ។

**ពន្ធជាក់លាក់ (Specific Tariff)៖** គឺជាការយកពន្ធទៅលើទំនិញនាំចេញនាំចូល គិតទៅលើឯកតានៃបរិមាណទំនិញ។ ឧទាហរណ៍: ការយកពន្ធ ៥០ដុល្លារ សម្រាប់រាល់ការនាំចូលកុំព្យូទ័រមួយគ្រឿង។

### ១.៣.១ របាំងមិនមែនពន្ធគយ

**ក. កូតា** ( Quota )

កូតា គឺជាការកម្រិតបរិមាណគឺជាការកំណត់បរិមាណនាំចូលទៅលើទំនិញណាមួយ ក្នុងកំឡុងពេលមួយជាក់លាក់។ នៅពេលដែលទំនិញណាមួយត្រូវបានគេកំណត់កូតានាំចូល ជាលទ្ធផលភ្លាមៗ គឺធ្វើឲ្យកើនឡើងនូវតម្លៃទំនិញនាំចូលឥតឈប់ឈររហូតដល់ពេលមួយដែលទីផ្សារមានភាពច្បាស់លាស់ឡើងវិញ។

**ខ. ពន្ធលើការនាំចេញ** ( Export Taxes )

ពន្ធលើការនាំចេញ គឺជាពន្ធដាក់កំហិតលើការនាំចេញទំនិញទៅកាន់ប្រទេសដទៃទៀត។ មានមូលហេតុច្រើននៃការយកពន្ធលើការនាំចេញនេះ។ ទី១ ដើម្បីរក្សាតម្លៃទំនិញក្នុងស្រុកឲ្យស្ថិតក្នុងកម្រិតទាប ព្រោះបើមានការនាំចេញទៅក្រៅស្រុកច្រើន នោះតម្លៃទំនិញក្នុងស្រុកនឹងឡើងថ្លៃ។ ទី ២ ដើម្បីកំហិតលើលំហូរនៃធនធានកំរសំខាន់ៗ ដូចជារ៉ែ មាស ត្បូង ។ល។ ទី៣ គឺដើម្បីអនុញ្ញាតអោយរដ្ឋទទួលបានចំនូល សម្រាប់យកទៅធ្វើការអភិវឌ្ឍដូចជាការកសាងហេដ្ឋារចនាសម្ព័ន្ធជាដើម។

**គ. ឧបត្ថម្ភធនលើការនាំចេញ** ( Export Subsidies )

ការឧបត្ថមធនលើការនាំចេញ គឺជាការចំណាយផ្ទាល់ ឬការបន្ធូរបន្ថយពន្ធ ឬការឧបត្ថម្ភជាកម្ចី ទៅដល់សហគ្រាសក្នុងស្រុក ដើម្បីជម្រុញអោយមានការផលិត និងនាំចេញកាន់តែច្រើន។ នៅពេលរដ្ឋាភិបាលធ្វើការឧបត្ថម្ភធនលើការនាំចេញដល់កម្រិតមួយ វានឹងធ្វើអោយតម្លៃទំនិញនៅក្នុងស្រុក ខ្ពស់ជាងតម្លៃនៅក្រៅស្រុក។ ឥទ្ធិពលនៃការឧបត្ថម្ភធននេះ មានលក្ខណៈបញ្ច្រាស់

គ្នាទាំងស្រុងទៅនឹងពន្ធគយ ពោលគឺ តម្លៃទំនិញនៅក្នុងប្រទេសនាំចេញនឹងកើនឡើង ឯតម្លៃទំនិញនៅក្នុងប្រទេសនាំចូលធ្លាក់ចុះ។

**ឃ. ការបន្ទាបថ្លៃ** (Dumping)

ការបន្ទាបថ្លៃ គឺជាការដែលសហគ្រាស ឬឧស្សាហកម្មមួយលក់ផលិតផលរបស់ខ្លួននៅលើទីផ្សារទាបជាងថ្លៃផលិតកម្មរបស់ខ្លួន។ ជាទូទៅក្រុមហ៊ុនឬសហគ្រាសធ្វើការបន្ទាបថ្លៃនៅពេលដែលខ្លួនចង់គ្រប់គ្រងទីផ្សារ និងកម្ចាត់គូរប្រកួតប្រជែង។ គេអាចទាញយកផលប្រយោជន៍មកវិញដោយការតម្លើងថ្លៃផលិតផលរបស់ខ្លួនតាមទម្រង់លក្ខណៈជាម៉ូណូប៉ូល។

**ខ. គោលនយោបាយផ្សេងៗរបស់រដ្ឋាភិបាល**

គោលនយោបាយពាណិជ្ជកម្មរបស់រដ្ឋាភិបាល ដើរតួនាទីសំខាន់ក្នុងការដាក់កំហិតលើលំហូរនៃទំនិញ និងសេវាកម្មពីប្រទេសមួយទៅប្រទេសមួយ។ គោលនយោបាយដែលជារបាំងពាណិជ្ជកម្មមិនមែនពន្ធសំខាន់ៗមានដូចជា៖

**ស្តង់ដារសុខភាព និងសុវត្ថិភាព (Health and security standard)៖** គឺជាការដាក់កម្រិតស្តង់ដារ ឬកម្រិតវាស់វែងស្តង់ដារសុខភាព និងសុវត្ថិភាពនៃទំនិញ និងសេវាកម្មរបស់ប្រទេសនីមួយៗ។ វាជាលក្ខខណ្ឌមួយដែលរឹតបន្តឹងការនាំចូលទំនិញ មិនមានគុណភាព ឬមិនសមស្របទៅតាមស្តង់ដារ ដែលជាការចង់បានរបស់ប្រទេសនាំចូល ហើយធ្វើការការនាំចូលថមថយ។

**របាំងរដ្ឋបាល (Red-tap barriers)៖** គឺជានយោបាយរារាំងការនាំចូលទំនិញ និងសេវាកម្មដោយប្រើនីតិវិធីរដ្ឋបាល ឬថ្លៃរដ្ឋបាល។ នីតិវិធីរដ្ឋបាល មានដូចជាការរៀបចំឯកសារនាំចេញ-នាំចូល ការកំនត់អោយស្តុកទំនិញ ការយកថ្លៃរដ្ឋាបាលខ្ពស់ជាដើម ដែលធ្វើអោយមានការពិបាកក្នុងការនាំចូល។

## ១.៤. អង្គការពាណិជ្ជកម្មពិភពលោក

### ១.៤.១ ប្រវត្តិនៃការកកើតអង្គការពាណិជ្ជកម្មពិភពលោក

អង្គការពាណិជ្ជកម្មពិភពលោក (WTO) ជាសមិទ្ធផលមួយក្រោយពីមានការបង្កើតកិច្ចព្រមព្រៀងទូទៅពន្ធគយ និងពាណិជ្ជកម្ម (General Agreement on Tariffs and Trade) និងចាប់បដិសន្ធិជាផ្លូវការនៅថ្ងៃទី០១ ខែមករា ឆ្នាំ១៩៩៥។ អង្គការពាណិជ្ជកិច្ចពិភពលោក គឺជាយន្តការមួយចម្បងសម្រាប់កិច្ចដំណើរការរបស់ប្រទេសជាសមាជិកទាំងអស់ ឲ្យមានលក្ខណៈជាសកលភាវូបនីយកម្ម និងសេរីភាវូបនីយកម្ម ដោយអនុវត្តស្ថិតនូវក្រោមលក្ខខណ្ឌក៏ដូចជាវិធាន និងបទ

បញ្ញត្តិទាំងឡាយដែលត្រូវបានតាក់តែង និងអនុម័តដោយអង្គការពាណិជ្ជកម្មពិភពលោក។ យ៉ាងណាមិញ ក្នុងនាមជាអង្គការអន្តរជាតិមួយដែលទទួលបន្ទុកក្នុងការសម្របសម្រួល និងការពារនូវផលប្រយោជន៍ពាណិជ្ជកម្ម របស់ប្រទេសជាសមាជិក WTO ទទួលខុសត្រូវក្នុងការតាមដានត្រួតពិនិត្យមើលការអនុវត្តកិច្ចព្រមព្រៀងរបស់ប្រទេសជាសមាជិកទាំងអស់ ហើយផ្តល់ជាវេទិកាចរចាសម្រាប់សមាជិកក្នុងការធ្វើសេរីភាវូបនីយកម្មលើទំនិញ និងសេវាកម្ម ជាពិសេសយន្តការនានាដើម្បីដោះស្រាយវិវាទពាណិជ្ជកម្មដល់ប្រទេសជាសមាជិក។ បច្ចុប្បន្ន អង្គការពាណិជ្ជកម្មពិភពលោក (WTO) មានសមាជិកចំនួន១៦៤ប្រទេស និងមានទីស្នាក់ការកណ្តាលនៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

ប្រព័ន្ធនៃការចរចារពាណិជ្ជកម្ម ត្រូវបានធ្វើឡើងតាមរយៈអង្គប្រជុំតុមូលនានា ក្រោមក្របខណ្ឌGATT។ កិច្ចប្រជុំតុមូលលើកដំបូងជជែកគ្នាផ្តោតលើប្រធានបទការកាត់បន្ថយពន្ធគយ។ ប៉ុន្តែការចរចារលើកក្រោយទៀតបានផ្តោតសំខាន់លើប្រធានបទដូចជា ការប្រឆាំងលើការបន្ទាបថ្លៃ (Anti-Dumping) និង បញ្ហាទាក់ទងទៅនឹងរបាំងមិនមែនពន្ធគយ។ អង្គប្រជុំលើកចុងក្រោយ គឺអង្គប្រជុំតុមូលអ៊ុយរូហ្គាយ (Uruguay Round) ពីឆ្នាំ១៩៨៦-១៩៩៤ ដែលឈានដល់ការបង្កើតឡើងនៃអង្គការពាណិជ្ជកម្មពិភពលោក (WTO)។ ទោះបីជាយ៉ាងណាក៏ដោយ ការចរចានេះមិនបានបញ្ចប់ត្រឹមនេះទេ។ ការចរចាខ្លះបានបន្តបន្ទាប់ពីអង្គប្រជុំតុមូលអ៊ុយរូហ្គាយ។ នៅខែកុម្ភៈ ឆ្នាំ១៩៩៧ កិច្ចព្រមព្រៀងត្រូវបានសម្រេចឡើងលើសេវាទូរគមនាគមន៍ជាមួយ រដ្ឋាភិបាលប្រទេសចំនួន ៦៩ ពោលគឺជម្រុញឲ្យមានការធ្វើសេរីភាវូបនីយកម្មឲ្យបានកាន់តែល្អប្រសើរ។ នៅឆ្នាំដដែល រដ្ឋាភិបាលប្រទេសចំនួន៤០ បានទទួលជោគជ័យលើការចរចាលុបបំបាត់ពន្ធគយលើពាណិជ្ជកម្មផលិតផលអេឡិចត្រូនិច ហើយរដ្ឋាភិបាលប្រទេសចំនួន៧០ ចុះកិច្ចព្រមព្រៀងលើការបើកចំហសេវាហិរញ្ញវត្ថុ ដូចជាធនាគារ ធានារ៉ាប់រង និងផ្សារមូលបត្រ។ លុះមកដល់ឆ្នាំ២០០០ ការជជែកពិភាក្សាចាប់ផ្តើមផ្តោតលើវិស័យកសិកម្ម និងសេវាកម្ម។ ប្រធានបទនេះបានដាក់បញ្ចូលទៅរបៀបវារៈ ក្នុងសន្និសីទអង្គការពាណិជ្ជកម្មពិភពលោកថ្នាក់រដ្ឋមន្ត្រីលើកទីបួន ក្នុងទីក្រុងដូហា ប្រទេសកាតា កាលពីខែវិច្ឆិកា ឆ្នាំ២០០១។

### ១.៤.២ លក្ខខណ្ឌក្នុងការចូលជាសមាជិក WTO

ពុំទាន់មានសេចក្តីថ្លែងជាផ្លូវការណាមួយ និយាយអំពីលក្ខខណ្ឌនានា ដែលតម្រូវឲ្យប្រទេសមួយអនុវត្តដើម្បីបានចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោកទេ។

ប្រទេសមួយអាចចូលជាសមាជិកបាន ដោយផ្អែកលើការព្រមព្រៀងជាមួយនឹងសមាជិកដទៃទៀត ដូចជា៖[9]

- ចរចារជាមួយប្រទេសជាសមាជិកនានា ដើម្បីចងអត្រាពន្ធលើទំនិញនាំចូល ឬ កំណត់អត្រាពន្ធខ្ពស់បំផុត ដែលត្រូវអនុវត្តលើទំនិញនាំចូល។
- ចរចារជាមួយប្រទេសជាសមាជិកនានា លើលក្ខខ័ណ្ឌនៃការបើកចំហាទីផ្សារ លើវិស័យសេវាកម្ម ដែលអនុញ្ញាតឲ្យអ្នកផ្តល់សេវាបរទេសមកអាចមកវិនិយោគក្នុងស្រុករបស់ខ្លួន។
- ត្រូវព្រមព្រៀងលើកំរិតនៃការឧបត្ថម្ភធនរបស់រដ្ឋ ចំពោះវិស័យកសិកម្ម ដែលអាចមានឥទ្ធិពលដល់ពាណិជ្ជកម្មអន្តរជាតិ។
- ធ្វើកែសម្រួលទៅលើច្បាប់ និងបទប្បញ្ញត្តិនានា ដែលគ្របដណ្តប់លើវិស័យពាណិជ្ជកម្មឲ្យសមស្របជាមួយនឹងវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោកមុនពេលចូលជាសមាជិក។

### ១.៤.៣ គោលបំណងរបស់អង្គការពាណិជ្ជកម្មពិភពលោក

អង្គការពាណិជ្ជកម្មពិភពលោក (WTO) មានគោលបំណងចំនួន៦ :

- បង្កើត និងអនុវត្តច្បាប់ស្តីពីពាណិជ្ជកម្មអន្តរជាតិ
- ផ្តល់នូវវេទិកាដើម្បីចរចា និងត្រួតពិនិត្យពីការអនុវត្តសេរីភាវូបនីយកម្មពាណិជ្ជកម្ម
- ដោះស្រាយជម្លោះពាណិជ្ជកម្ម
- បង្កើនតម្លាភាពទាក់ទងនឹងដំណើរការសេចក្តីសម្រេចចិត្ត
- ពង្រឹងកិច្ចសហប្រតិបត្តិការ ជាមួយនឹងស្ថាប័នសេដ្ឋកិច្ចអន្តរជាតិធំៗទាក់ទងនឹងការគ្រប់គ្រងការអភិវឌ្ឍសេដ្ឋកិច្ចសកលលោក
- ជួយបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ឲ្យទទួលបានផលប្រយោជន៍ពីប្រព័ន្ធដោះដូរពាណិជ្ជកម្មសកលលោក។

[9] Sok. S. (2005). *Lessons from Cambodia's Entry into the World Trade Organization. [មេរៀនពីកម្ពុជាក្នុងការចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក].* (Tokyo: Asian Development Bank Institute)

# ជំពូកទី ២
# សេរីភាវូបនីយកម្មពាណិជ្ជកម្មក្នុងប្រទេសកម្ពុជា

## ២.១ ស្ថានភាពសេដ្ឋកិច្ចកម្ពុជា

បន្ទាប់ពីការទទួលបានសន្តិភាពពេញលេញនាចុងទសវត្សរ៍ទី ៩០ សេដ្ឋកិច្ចកម្ពុជាត្រូវបានគេមើលឃើញថា មានការរីកចម្រើនយ៉ាងឆាប់រហ័ស ស្របទៅតាមគោលដៅនៃផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ដែលបានដាក់ចេញដោយរាជរដ្ឋាភិបាល។ ជាក់ស្តែងក្នុងឆ្នាំ ២០១៦ កម្ពុជាសម្រេចបានកំណើនសេដ្ឋកិច្ចប្រមាណ ៧% ដែលមានផលិតផលក្នុងស្រុកសរុប (Real GDP) ប្រមាណ ១៩,៩៥០ លានដុល្លារអាមេរិច[10]។ ក្នុងនោះវិស័យឧស្សាហកម្មបានកើនឡើង ១១.៤% សេវាកម្ម ៦.៧% និងកសិកម្ម ០.៥%។ រីឯប្រាក់ចំណូលជាមធ្យមរបស់ប្រជាពលរដ្ឋម្នាក់ៗ (GDP per capita) បានកើនដល់ប្រមាណ ១,៣០០ ដុល្លារអាមេរិក[11] ដែលជាកត្តាមួយធ្វើឲ្យធនាគារពិភពលោកចាត់កម្ពុជាចេញពីក្រុមប្រទេសមានចំណូលទាប (Low-Income Countries) ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប (Lower-Middle-Income Countries)។

**ក្រាហ្វិកទី ២.១៖ កំណើនសេដ្ឋកិច្ចកម្ពុជាពីឆ្នាំ ២០០២ ដល់ ២០១៦**




**ប្រភព:** *វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ, ២០១៦*

[10] រង្សី វិស្សុត, *កម្ពុជា: អតីតកាល បច្ចុប្បន្ន និងអនាគត,* (បទបង្ហាញនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ០៣ កុម្ភ: ២០១៧) ។

[11] ធនាគារជាតិនៃកម្ពុជា, *របាយការណ៍ប្រចាំឆ្នាំ ២០១៦*, (ភ្នំពេញ៖ ២០១៦), ៦ ។

ទោះបីជាប្រជាជនកម្ពុជាភាគច្រើនជាកសិករក៏ដោយ គេមើលឃើញថា បច្ចុប្បន្នការចូលរួមនៃវិស័យកសិកម្មក្នុងសេដ្ឋកិច្ចជាតិត្រូវបាន កាន់តែរួមតូច ខណៈដែលការរួមចំណែករបស់វិស័យឧស្សាហកម្ម កាន់រីកតែធំ។ ការថយចុះនេះ ដោយហេតុតែមានការរីកលូតលាស់ខ្លាំងនៅក្នុងអនុវិស័យសំខាន់ៗមួយចំនួន៣ គឺ ទី១ វិស័យកាត់ដេរ (មានប្រមាណ ១.៧៣% នៃ GDP ឆ្នាំ ២០១៥) ទី២ គឺវិស័យសំណង់ (មានប្រមាណ ១.២៥% នៃGDP ឆ្នាំ ២០១៥) និងទីបី គឺ វិស័យទេសចរណ៍[12] ។

**ក្រាហ្វិកទី២.២៖ ការចូលរួមនៃវិស័យចម្បងទាំងបីនៅក្នុងសេដ្ឋកិច្ចកម្ពុជា**




ប្រភព: *វិទ្យាស្ថានជាតិស្ថិតិ នៃក្រសួងផែនការ, ២០១៦*

## ២.១.១ ស្ថានភាពនៃវិស័យពាណិជ្ជកម្ម

កម្ពុជាចាប់ផ្តើមប្រើប្រាស់យន្តការសេដ្ឋកិច្ចទីផ្សារ (Market Economy) ទាំងពីចុងទសវត្សរ៍ទី ៨0 មកម្ល៉េះ។ ប៉ុន្តែកំណែទម្រង់សេដ្ឋកិច្ចនាពេលនោះមានភាពយឺតយ៉ាវ ដោយសារសង្គ្រាមស៊ីវិលក្នុងស្រុកជាបន្ទាប់បន្ត។ រយៈកាលក្រោយមក កម្ពុជាបានចាប់ផ្តើមនៃដំណើរការកំណែទម្រង់សេដ្ឋកិច្ច របស់ខ្លួនម្តងទៀត ដោយបានធ្វើសមាហរណកម្មសេដ្ឋកិច្ចទៅក្នុងទីផ្សារពិភពលោក និងតំបន់។ ជាក់ស្តែងកម្ពុជាបានចូលជាសមាជិកសហគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (ASEAN) នៅ

[12] ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, *របាយការណ៍បូកសរុបកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ប្រចាំឆ្នាំ ២០១៤-២០១៥ និងទិសដៅការងារសម្រាប់ឆ្នាំ ២០១៥-២០១៦*, (ភ្នំពេញ ២០១៥), ៣។

ថ្ងៃទី ៣០ មេសា ១៩៩៩ និងក្រោយមកបានក្លាយជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO) នៅថ្ងៃទី ១៣ កញ្ញា ២០០៤ ។[13]

តាមរយៈសមាហរណកម្មសេដ្ឋកិច្ចនេះ វិស័យពាណិជ្ជកម្មរបស់កម្ពុជាមានភាពរីកចំរើនគួរឲ្យកត់សម្គាល់។ វិស័យពាណិជ្ជកម្មនេះក៏ជាកត្តាចម្បងក្នុងការជម្រុញកំណើនសេដ្ឋកិច្ចជាតិ និងក៏ដូចជាការកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋផងដែរ។

**ក្រាហ្វិកទី២.៣៖ ស្ថិតិការនាំចេញ នាំចូល និង ទំហំពាណិជ្ជកម្មសរុប**




**ប្រភព:** *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៦*

* ទិន្និន័យលម្អិតអំពី ទំហំពាណិជ្ជកម្មរបស់កម្ពុជា ដែលចេញផ្សាយក្នុងរបាយការណ៍របស់អង្គការពាណិជ្ជកម្មពិភពលោកឆ្នាំ ២០១៥ មាននៅក្នុងឧបសម្ព័ន្ធទី ១ ។

### ក. ការនាំចេញ

ការនាំចេញទំនិញសរុបរបស់កម្ពុជាក្នុងឆ្នាំ ២០១៥ មានកំណើនក្នុងអត្រា ១៩.២%។ ការនាំចេញផលិតផលកាត់ដេរមានចំណែករហូតដល់ទៅ ៣/៤ នៃការនាំចេញសរុបរបស់កម្ពុជា ហើយមានកំណើនប្រមាណ ១៥.៥% ក្នុងឆ្នាំ ២០១៥។ ផលិតផលអង្ករ និងកៅស៊ូក៏មានកំណើននៃការនាំចេញខ្ពស់ផងដែរ ខណៈដែរផលិតផល កសិកម្ម ត្រី បារី ។ល។ បានធ្លាក់ចុះ។

[13] Chab. F. និង Cheang. V., ASEAN-China Free Trade and Cambodian Industries [ពាណិជ្ជកម្មសេរីកម្ពុជា-ចិន និង វិស័យឧស្សាហកម្មរបស់កម្ពុជា], (Phnom Penh: Cambodia Institutes for Cooperation and Peace, 2010), 17 ។

ដោយផ្អែកលើស្ថានភាពបច្ចុប្បន្ន ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុរំពឹងថា ការនាំចេញក្នុងឆ្នាំ ២០១៧ អាចមានការថមថយ ដោយសារសេដ្ឋកិច្ចរបស់ប្រទេសជាដៃគូរទទួលយក សម្លៀកបំពាក់ធំៗ មួយចំនួននៅសហភាពអឺរ៉ុប រួមទាំងចក្រភពអង់គ្លេស អាឡឺម៉ង់ អេស្ប៉ាញ អ៊ីតាលី ជាដើម ត្រូវបានព្យាករថា នឹងមានកំណើនយឺតក្នុងឆ្នាំ ២០១៧។ បណ្តាប្រទេសទាំងនេះ បានស្រូបយកចំណែក លើសពី ១/៤ នៃការនាំចេញផលិតផលកាត់ដេរសរុបរបស់កម្ពុជា។[14]

**តារាងទី ២.១ ៖ ដៃគូ និងមុខទំនិញនាំចេញ របស់កម្ពុជាឆ្នាំ ២០១៥**

| ប្រទេសនាំចេញសំខាន់ទាំង ១០ | | | មុខទំនិញនាំចេញសំខាន់ទាំង ១០ | | |
|---|---|---|---|---|---|
| **ប្រទេស** | **ទឹកប្រាក់ ($)** | **ភាគរយ** | **មុខទំនិញ** | **ទឹកប្រាក់ ($)** | **ភាគរយ** |
| អាមេរិក | 2,136,784,183 | 25.11 | សម្លៀកបំពាក់ | 5,550,192,432 | 64.97 |
| អង់គ្លេស | 869,038,820 | 10.21 | ស្បែកជើង | 637,000,369 | 7.46 |
| អាឡឺម៉ង់ | 748,379,618 | 8.80 | សម្លៀកបំពាក់ (ដេរដៃ) | 366,281,097 | 4.29 |
| ជប៉ុន | 517,552,437 | 6.72 | បរិក្ខារអគ្គិសនី | 321,290,799 | 3.76 |
| កាណាដា | 551,035,209 | 6.48 | ធញ្ញជាតិ (Cereal) | 285,643,310 | 3.34 |
| ចិន | 405,515,210 | 4.77 | គ្រឿងបន្លាស់យានយន្ត | 281,294,840 | 3.29 |
| ថៃ | 345,200,963 | 4.07 | រោម និងស្បែកសត្វ | 166,121,378 | 1.94 |
| បារាំង | 298,260,225 | 3.51 | កៅស៊ូ | 163,340,997 | 1.91 |
| បែលហ្សិក | 282,473,799 | 3.32 | ផលិតផលធ្វើពីស្បែក | 95,838,553 | 1.12 |
| អេស្ប៉ាញ | 273,605,948 | 3.22 | វាយនភ័ណ្ឌ | 86,064,342 | 1.01 |
| ផ្សេងៗ | 2,025,812,153 | 23.81 | ផ្សេងៗ | 589,365,552 | 6.90 |

**ប្រភព:** *Global EDGE, 2017*

### ខ. ការនាំចូល

ការនាំចូលសរុបក្នុងឆ្នាំ ២០១៥ កើនឡើងប្រមាណ ១៣.៥%។ តម្លៃនាំការនាំចូលសម្ភារៈសំណង់ អាហារ និងភេសជ្ជៈ ព្រមទាំងមុខទំនិញផ្សេងទៀតមានការថមថយ ប៉ុន្តែការនាំចូលក្រណាត់និងអំបោះ ផលិតផលតេលសិលា និងយានយន្តមានការកើនឡើង ដែលឆ្លុះបញ្ចាំងពី

[14] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, របាយការណ៍តាមដានវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា: ការវាយតម្លៃពាក់កណ្តាលឆ្នាំ ២០១៦, (ភ្នំពេញ ២០១៦), ២១ ។

កំណើនខ្ពស់នៃវិស័យកាត់ដេរ និងការប្រើប្រាស់។ ម៉្យាងទៀតការថមថយនៃសម្ភារៈសំណង់បង្ហាញពីការថមថយនៃសកម្មភាពសំណង់ក្នុងស្រុក ខណៈដែលការថមថយនៃការនាំចូលម្ហូបអាហារ និងភេសជ្ជៈ បង្ហាញពីការថមថយនៃសកម្មភាពអាជីវកម្មសណ្ឋាគារ និងភោជនីយដ្ឋាន ប៉ុន្តែក៏សរបញ្ជាក់ឲ្យឃើញពីកំណើននៃផលិតកម្មក្នុងស្រុកជំនួសឲ្យការនាំចូលផងដែរ។[15]

**តារាងទី ២.២៖ ដៃគូ និងមុខទំនិញនាំចូល របស់កម្ពុជាឆ្នាំ ២០១៥**

| ប្រទេសនាំចេញសំខាន់ទាំង ១០ | | | មុខទំនិញនាំចេញសំខាន់ទាំង ១០ | | |
|---|---|---|---|---|---|
| ប្រទេស | ទឹកប្រាក់ ($) | ភាគរយ | មុខទំនិញ | ទឹកប្រាក់ ($) | ភាគរយ |
| ចិន | 3,926,204,044 | 39.11 | ក្រណាត់ | 1,984,795,779 | 18.60 |
| ថៃ | 1,561,488,197 | 15.55 | គ្រឿងបន្លាស់យានយន្ត | 1,147,973,659 | 10.76 |
| វៀតណាម | 926,966,000 | 9.23 | អំបោះ | 962,590,882 | 9.02 |
| ហុងកុង | 714,281,221 | 7.12 | គ្រឿងចក្រឧស្សាហកម្ម | 670,407,745 | 6.28 |
| សិង្ហបុរី | 503,288,445 | 5.01 | ត្បូង និងលោហៈមានតម្លៃ | 599,114,574 | 5.62 |
| កូរ៉េខាងត្បូង | 459,554,107 | 4.58 | បរិក្ខាអគ្គិសនី | 512,189,888 | 4.80 |
| ជប៉ុន | 442,953,826 | 4.21 | កប្បាស | 380,962,244 | 3.57 |
| ឥណ្ឌូនេស៊ី | 335,539,429 | 3.34 | ប្លាស្ទិច | 317,804,414 | 2.98 |
| អាមេរិក | 229,489,486 | 2.29 | ក្រដាស | 242,479,582 | 2.27 |
| ម៉ាឡេស៊ី | 187,479,674 | 1.87 | ថ្នាំជក់ | 235,702,176 | 2.21 |
| ផ្សេងៗ | 771,595,895 | 7.69 | ផ្សេងៗ | 3,614,902,489 | 33.88 |

**ប្រភព:** *Global EDGE, 2017*

### គ. ជញ្ជីងពាណិជ្ជកម្ម

ជញ្ជីងពាណិជ្ជកម្មកម្ពុជានៅមានឱនភាពនៅឡើយ ដោយសារទំហំនៃការនាំចូលនៅតែធំជាងទំហំនៃការនាំចេញ បើទោះបីជារាជរដ្ឋាភិបាលបានខិតខំ ជម្រុញឲ្យមានការនាំចេញទៅកាន់បរទេសកាន់តែច្រើនក៏ដោយ។ នេះក៏ព្រោះតែទំនិញនាំចេញរបស់កម្ពុជា ភាគច្រើនជាប្រភេទ

[15] ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, *របាយការណ៍តាមដានវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា: ការវាយតម្លៃពាក់កណ្ដាលឆ្នាំ ២០១៦*, (ភ្នំពេញ ២០១៦), ២៣ ។

ទំនិញឧស្សាហកម្មធន់ស្រាល និងទំនិញកសិកម្មមិនទាន់កែច្នៃ ខណៈដែលតម្រូវការនៃការនាំចូលកាន់តែកើនឡើងខ្ពស់។

**ក្រាហ្វិកទី២.៤៖ ជញ្ជីងពាណិជ្ជកម្មកម្ពុជា**




ប្រភព: *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៦*

## ២.១.២ ការបើកចំហនៃវិស័យពាណិជ្ជកម្មរបស់កម្ពុជា

ប្រទេសកម្ពុជាជាប់ចំណាត់ថ្នាក់ទី ៩៨ ក្នុងចំណោមប្រទេសចំនួន ១៣៦ ដែលមានការបើកចំហផ្នែកពាណិជ្ជកម្ម។ គេអាចវាស់វាបានដោយប្រើ Enabling Trade Index ដែលក្នុងនោះមានរួមបញ្ចូលនូវសូចនាករសំខាន់ៗចំនួន ៧ សម្រាប់ធ្វើការវិនិច្ឆ័យ។ សូចនាករទាំងនោះរួមមាន[16] ៖

១. លទ្ធភាពនៃការចូលទៅកាន់ទីផ្សារក្នុងស្រុក (Domestic market access)

២. លទ្ធភាពនៃការចូលទៅកាន់ទីផ្សារបរទេស (Foreign market access)

៣.ប្រសិទ្ធភាព និងតម្លាភាពនៃរដ្ឋបាលព្រំដែន (Efficiency and transparency of border administration)

៤. លទ្ធភាព និងគុណភាពហេដ្ឋារចនាសម្ព័ន្ធ (Availability and quality transportation infrastructure)

[16] World Economic Forum & Global Alliance for Trade Facilitation, *The Global Enabling Trade Report 2016 [របាការណ៍ការបើកឲ្យមានពាណិជ្ជកម្មពិភពលោក ២០១៦]*, (2016), 88-89.

៥. លទ្ធភាព និងគុណភាពសេវាកម្មដឹកជញ្ជូន (Availability and quality transportation service)

៦. លទ្ធភាព និងការប្រើប្រាស់បច្ចេកវិទ្យាទំនាក់ទំនងព័ត៌មាន (Availability and use of ICTs)

៧.បរិយាសកាសប្រតិបត្តិការ (Operating environment)

**ក្រាហ្វិកទី ២.៥ ៖ Cambodia's Enabling Trade Index 2015**




ប្រភព: *World Economic Forum, 2016*

សូចនាករទាំង ៧ ត្រូវបានស្ថាប័ន World Economic Forum កំនត់ចន្លោះពិន្ទុពី ១ ដល់ ៧ ដែលក្នុងនោះ ក្នុងចំណោម ១៣៦ប្រទេស កម្ពុជាទទួលបានពិន្ទុដូចខាងក្រោម៖

- សូចនាករទី ១ ៖ ទទួលបាន ៤.២ ពិន្ទុ (ចំណាត់ថ្នាក់ ១០៧)
- សូចនាករទី ២ ៖ ទទួលបាន ៥.៩ ពិន្ទុ (ចំណាត់ថ្នាក់ ៥)
- សូចនាករទី ៣ ៖ ទទួលបាន ៣.៦ ពិន្ទុ (ចំណាត់ថ្នាក់ ១១៦)
- សូចនាករទី ៤ ៖ ទទួលបាន ២.៦ ពិន្ទុ (ចំណាត់ថ្នាក់ ១១៣)
- សូចនាករទី ៥ ៖ ទទួលបាន ៣.៧ ពិន្ទុ (ចំណាត់ថ្នាក់ ៨៧)
- សូចនាករទី ៦ ៖ ទទួលបាន ៣.៣ ពិន្ទុ (ចំណាត់ថ្នាក់ ១០៥)
- សូចនាករទី ៧ ៖ ទទួលបាន ៤.០ ពិន្ទុ (ចំណាត់ថ្នាក់ ៩៤)

** ទិន្និន័យលម្អិតអំពី Cambodia's Enabling Trade Index មានក្នុងឧបសម្ព័ន្ធទី ២*

### ២.១.៣ ស្ថានភាពនៃការវិនិយោគផ្ទាល់ពីបរទេស

ក្នុងឆ្នាំ ២០១៤ ប្រទេសកម្ពុជាមានសហគ្រាសវិនិយោគផ្ទាល់ពីបរទេសចំនួនប្រមាណពី ១,០០០ ទៅ ១,២០០ សហគ្រាស ដែលភាគច្រើនស្ថិតនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ និងស្បែកជើង ដែលមានដល់ទៅ ៦៥៦សហគ្រាស[17] ។ ក្នុងឆ្នាំ ២០១៥ វិនិយោគផ្ទាល់ពីបរទេសមានសមាមាត្រ ១០,៧% នៃផលិតផលក្នុងស្រុកសរុប ដែលក្នុងនោះបែងចែកជាវិស័យហិរញ្ញវត្ថុ ២៥% វិស័យកម្មន្ត ១៨% វិស័យអចលនទ្រព្យ ១៣% និងវិស័យកសិកម្ម ១១% ។ល។ ទំហំនៃការវិនិយោគផ្ទាល់ពីបរទេសក្នុងឆ្នាំ ២០១៥ មានប្រមាណ ១,៧០១ លានដុល្លារអាមេរិក។

**ក្រាហ្វិកទី២.៦៖ កំណើននៃការវិនិយោគផ្ទាល់ពីបរទេស**




**ប្រភព:** *ធនាគារជាតិនៃកម្ពុជា, ២០១៦*

ផ្អែកតាមប្រភពដើមនៃទីតាំងភូមិសាស្ត្រនៃវិនិយោគផ្ទាល់បរទេស ប្រទេសកម្ពុជាទទួលបានវិនិយោគផ្ទាល់ ភាគច្រើនពីប្រទេសអាស៊ី ដែលមានចំនួន ៩០ភាគរយ នៃវិនិយោគផ្ទាល់បរទេសសរុប ក្រៅពីនេះ គឺមកពីទ្វីបអឺរ៉ុប និងអាមេរិក។

[17] វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា, *របាយការណ៍អំពីវិនិយោគផ្ទាល់ពីបរទេសឆ្នាំ ២០១៤*, (ភ្នំពេញ, ២០១៦), ២, ៧-៩។

**តារាងទី២.៣ ៖ ទឹកប្រាក់វិនិយោគផ្ទាល់ពីបរទេសទៅតាមប្រទេសនីមួយៗ (គិតជាលានដុល្លារ)**

| វិស័យ / ប្រទេស | ក | ខ | គ | ឃ | ង | ច | ឆ | ជ | ឈ | ញ | សរុប |
|---|---|---|---|---|---|---|---|---|---|---|---|
| ចិន | ៥៣ | ១៥ | ១៦២ | ៨៣ | ៦២ | ១០ | | | ៧៥ | ៥០ | ៥១១ |
| ហុងកុង | ១០ | ២ | ៤៣ | ១៦ | ៣១ | | | | ៦១ | ៧៤ | ២៣៧ |
| វៀតណាម | ១២៥ | | ៧ | ៥១ | | | | ៩ | | ១ | ១៩២ |
| ជប៉ុន | | | ១៣ | ៦១ | ២៤ | | ៦២ | | ១៥ | ១០ | ១៨៥ |
| សិង្ហបុរី | ១១ | | ១៧ | ១៦ | ៣ | | | | ១១៣ | ៨ | ១៦៩ |
| អង់គ្លេស | ៧ | | ៤៦ | ១ | ២ | ៥ | | | ១ | ៦៦ | ១២៨ |
| អាមេរិក | ១ | | ៤ | ៦៩ | | | | ៦ | ៣៦ | ៩ | ១២៤ |
| តៃវ៉ាន់ | | | ៤៥ | ៣៣ | | | | | ១៩ | ៨ | ១០៦ |
| ថៃ | ១១ | | | ៣៨ | ៥ | | ១ | | ២ | ៣៧ | ៩៥ |
| កូរ៉េខាងត្បូង | ១២ | | ១៦ | ២០ | ៣២ | | | | ៥ | ៨ | ៩២ |
| ផ្សេងៗ | ៣ | ២ | ៣៧ | ១៥១ | ៦៧ | | ៦ | | ៤៥ | ៦ | ៣១៧ |
| **សរុប** | **២៣២** | **១៩** | **៣៩០** | **៥៣៩** | **២២៨** | **១៥** | **៦៩** | **១៥** | **៣៧០** | **២៧៨** | **២,១៥៥** |

**ប្រភព:** *ធនាគារជាតិនៃកម្ពុជា, ២០១៦*

**<u>សំគាល់៖</u>** **ក**៖កសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, **ខ**៖ប្រតិបត្តិការ និងអាជីវកម្មធនធានរ៉ែ, **គ**៖កម្មន្តសាល, **ឃ**៖ហិរញ្ញវត្ថុ, **ង**៖សកម្មភាពស្នាក់នៅ និងអាហារ, **ច**៖ព័ត៌មានវិទ្យា និងទូរគមនាគមន៍, **ឆ**៖សំណង់, **ជ**៖អគ្គិសនី, **ឈ**៖អចលនទ្រព្យ, **ញ**៖ផ្សេងៗ។

## ២.២ សមាហរណកម្មសេដ្ឋកិច្ច

ចាប់តាំងពីចុងទសវត្សរ៍ ៨០ ហើយជាពិសេសនៅដើមទសវត្សរ៍៩០ កម្ពុជាបានចាប់ផ្តើមធ្វើសេរីភាវូបនីយកម្ម ក្នុងវិស័យពាណិជ្ជកម្ម និងសមាហរណកម្មជាបន្តបន្ទាប់ ដើម្បីពង្រឹងនូវចំណងទំនាក់ទំនង និងកិច្ចសហប្រតិបត្តិការជាមួយប្រជាជាតិនានានៅលើពិភពលោក។ ក្នុងនោះកម្ពុជាបានចូលជាសមាជិកនៃអង្គការពាណិជ្ជកម្មពិភពលោក និងសមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ ឬ អាស៊ាន ដែលធ្វើឲ្យវិស័យពាណិជ្ជកម្មកម្ពុជាកាន់តែមានសន្ទុះទៅមក និងនាំមកនូវផលប្រយោជន៍សេដ្ឋកិច្ចជាច្រើនជូនប្រជាជន។

### ២.២.១ អង្គការពាណិជ្ជកម្មពិភពលោក (WTO)

រដ្ឋាភិបាលកម្ពុជា បានដាក់ពាក្យស្នើសុំចូលជាសមាជិក នៃអង្គការពាណិជ្ជកម្មពិភពលោក តាំងតែពីខែតុលា ឆ្នាំ ២០០១ ហើយទើបតែទទួលបានសមាជិកភាពពេញលេញក្នុងថ្ងៃទី ១៩ ខែកញ្ញា ឆ្នាំ ២០០៤។ ការចូលរួមជាមួយអង្គការអន្តរជាតិមួយនេះ ពិតជាមានសារៈសំខាន់ណាស់សម្រាប់កម្ពុជា ក្នុងការធ្វើលើកកម្ពស់វិស័យពាណិជ្ជកម្មអន្តរជាតិ ដើម្បីជម្រុញកំណើនសេដ្ឋកិច្ច។

កម្ពុជាបានបង្កើតនូវគោលការណ៍មួយចំនួន សម្រាប់ការចរចារជាមួយសមាជិកដទៃរបស់អង្គការពាណិជ្ជកម្មពិភពលោក។ ចំណុចសំខាន់ទាំង ៦ នៃយុទ្ធសាស្ត្រ[18] របស់កម្ពុជាគឺៈ

**ក. ពេលវេលាៈ** កម្ពុជាបានចំណាយពេលវេលាសមរម្យមួយដើម្បីសេចក្តីព្រាង និងអនុម័តនូវច្បាប់មួយចំនួនធំ ដើម្បីបង្កើតឲ្យមានរបបពាណិជ្ជកម្មមួយ ស្របទៅតាមវិធានរបស់អង្គការពាណិជ្ជកម្មពិភពលោក។

**ខ. ការធ្វើសម្បទានពន្ធគយៈ** កម្ពុជាបានកែទម្រង់លើរបបពន្ធគយរបស់ខ្លួន ដោយកាត់បន្ថយក្រុមពន្ធគយពី ១២ក្រុម ទៅ ០៤ក្រុម។ ដូច្នេះបន្ទាប់ពីការកែទម្រង់ ទំនិញនាំចូលទាំងអស់ជាប់ពន្ធត្រឹមអត្រា 0% ៧% ១៥% ឬ៣៥%។

**គ. ទិសដៅនៃការនាំចេញៈ** កម្ពុជាបានអនុញ្ញាតឲ្យឧស្សាហកម្មនាំចេញមួយចំនួនមានសិទ្ធនាំចូលនូវទុនទំនិញពាក់កណ្តាលសម្រេច និងវត្ថុធាតុដើមសម្រាប់បម្រើផលិតកម្ម ដោយមិនបង់ពន្ធលើការនាំចូល។

**ឃ. ការធ្វើឲ្យបរិយាសកាសវិនិយោគល្អប្រសើរៈ** កម្ពុជាបានពង្រឹងភាពប្រាកដនិយម ចំពោះអ្នកវិនិយោគ ដោយការបង្កើតឲ្យមាននូវក្របខ័ណ្ឌច្បាប់សម្រាប់គ្រប់គ្រងពាណិជ្ជកម្ម ដែលមានលក្ខណៈសេរី និងបន្តការអភិវឌ្ឍប្រព័ន្ធហេដ្ឋារចនាសម្ព័ន្ធ និងធនធានមនុស្ស។

**ង. ភាពអាចប្រែប្រួលបានចំពោះវិស័យកសិកម្មៈ** កម្ពុជាបានរក្សាទុកការការពារតាមរយៈពន្ធគយ ឲ្យនៅកម្រិតទាបបំផុត សម្រាប់ការពារផលិតកម្មនៃវិស័យកសិកម្ម និងរក្សាសិទ្ធិក្នុងការផ្តល់ការឧបត្ថម្ភធនចំពោះអ្នកផលិតក្នុងស្រុក ។

**ច. ការធានាផលប្រយោជន៍ចំពោះសុខភាពសាធារណៈ** ៖ កម្ពុជារក្សាសិទ្ធិក្នុងការទទួលនូវជំនួយថ្នាំពេទ្យ រួមទាំងសិទ្ធិក្នុងការនាំចូលផលិតផលឱសថដែលមានតម្លៃថោក ខណៈដែលកម្ពុជាពឹងពាក់ទាំងស្រុងលើការនាំចូលថ្នាំពេទ្យដើម្បីប្រឆាំងនឹងជំងឺផ្សេងៗ ។

[18] ចម ប្រសិទ្ធ, *កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក* (ភ្នំពេញៈ ក្រសួងពាណិជ្ជកម្ម, ២០០៤), ០៩ ។

### ២.២.២ សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍

សមាគមន៍ប្រជាជាតិអាស៊ីអាគ្នេយ៍ (Association of Southeast Asian Nations – ASEAN) ត្រូវបានបង្កើតឡើងនៅថ្ងៃទី ៨ សីហា ១៩៦៧ ដោយសមាជិក ៥ប្រទេសគឺ ឥណ្ឌូនេស៊ី ម៉ាឡេស៊ី ហ្វីលីពីន សិង្ហបុរី និងថៃ។ ក្រោយមកសមាជិកបានកើនឡើងរហូតដល់ ១០ប្រទេសដូចសព្វថ្ងៃ ដែលមានសមាជិកបន្ថែមដូចជា ប្រ៊ុយណេ (១៩៨៤) វៀតណាម (១៩៩៥) ឡាវ (១៩៩៧) មីយ៉ាន់ម៉ា (១៩៩៧) និងកម្ពុជា (១៩៩៩)។

**ក. តំបន់ពាណិជ្ជកម្មសេរីអាស៊ាន** (AFTA)

ក្នុងឆ្នាំ ១៩៩២ ក្នុងកិច្ចប្រជុំកំពូលអាស៊ានលើកទី ៤ សមាជិកអាស៊ានបានឯកភាពគ្នាបង្កើតនូវ តំបន់ពាណិជ្ជកម្មសេរីអាស៊ាន (ASEAN Free Trade Area – AFTA) ដែលមានគោលបំណងជម្រុញពាណិជ្ជកម្មក្នុងតំបន់ និងបង្កើនឧត្តមភាពប្រកួតប្រជែងរបស់តំបន់។ ដើម្បីសម្រេចគោលបំណងនេះ AFTA បានប្រើប្រាស់ គោលការណ៍រួមស្តីពីប្រព័ន្ធអនុគ្រោះគយ (Common Effective Preferential Tariff Scheme ឬហៅកាត់ថា CEPT Scheme) ដើម្បីលុបចោលនូវរបាំងពន្ធគយ។ គោលការណ៍នេះត្រូវបានអនុវត្តជាបណ្តើរៗ នឹងឈានទៅលុបចោលទាំងស្រុងរបាំងពន្ធគយយ៉ាងយូរត្រឹមឆ្នាំ ២០១០សម្រាប់អាស៊ានទាំង ៦ និង ២០១៥ ចំពោះសមាជិក ៤ទៀត (កម្ពុជា ឡាវ មីយ៉ាន់ម៉ា និងវៀតណាម) ។

**តារាងទី ២.៤ ៖ វិសាលភាពនៃទំនិញតាមប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន**

| ប្រទេសផ្តល់ការអនុគ្រោះ | ប្រទេសដែលទទួលផលពីការអនុគ្រោះ | | | | ពន្ធគយនៃប្រព័ន្ធអនុគ្រោះសមាហរណកម្មអាស៊ាន |
|---|---|---|---|---|---|
| | កម្ពុជា | ឡាវ | មីយ៉ាន់ម៉ា | វៀតណាម | |
| ប្រ៊ុយណេ | ៨ | ១៤ | ៧៩ | ១ | 0% |
| ឥណ្ឌូនេស៊ី | ៤០ | ២១ | ២៦២ | ៧១ | 0-៥% |
| ម៉ាឡេស៊ី | ១៧៤ | ៨២ | ២៨៤ | ២៣៤ | 0% |
| ហ្វីលីពីន | ៦៤ | ៧៦ | ២០៦ | ៧៩ | 0% |
| សិង្ហបុរី | - | - | - | - | - |
| ថៃ | ៣៤០ | ៣០០ | ៨៥០ | - | 0-៥% |
| សរុប | ៦៣១ | ៤៩៣ | ១,៦៨១ | ៥៣៥ | |

**ប្រភព:** *ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៣*

កិច្ចព្រមព្រៀងតំបន់ពាណិជ្ជកម្មសេរី (AFTA) បានកំណត់អត្តសញ្ញាណផលិតផល ចូលទៅក្នុងបញ្ជីចំនួន ៤ គឺ[19]

**១. បញ្ជីដាក់បញ្ចូល (Inclusive List ឬ IL):** បញ្ជីនេះរួមបញ្ចូលទំនិញទាំងអស់ ដែលមិនស្ថិតនៅក្នុងតារាងវេទយិតភាព និងតារាងអនុគ្រោះទូទៅ។ វាមាន ២ ផ្លូវ (Track) គឺ៖

- **ផ្លូវធម្មតា:** ផលិតផលក្នុងបញ្ជី IL ត្រូវកាត់បន្ថយអត្រាពន្ធគយជាដំណាក់កាលៗ ។

- **ផ្លូវលឿន:** សម្រាប់ផលិតផលមួយចំនួន ដូចជា ប្រេងខ្លាញ់ ផលិតផលរ៉ែ សារធាតុគីមី ស្បែក និងផលិតផលធ្វើអំពីស្បែក ផលិផលក្រដាស វាយនភ័ណ្ឌ សម្លៀកបំពាក់ ស៊ីម៉ង់ត៍ ត្បូងមានតម្លៃ ផលិតផលធ្វើពីលោហៈធាតុ គ្រឿងម៉ាស៊ីន គ្រឿងបរិក្ខារអគ្គិសនី និងផលិតផលពោងចក្រដទៃទៀត ត្រូវការកាត់បន្ថយពន្ធគយជាបន្ទាន់។

**២. បញ្ជីទំនិញដែលមានវេទយិទភាព (Sensitive List ឬ SL):** បញ្ជីនេះគឺសម្រាប់ផលិតផលកសិកម្មមិនទាន់កែច្នៃ ដែលប្រទេសជាសមាជិកគិតថាមានវេទយិទភាពសម្រាប់ពួកគេ។ ផលិតផលនៅក្នុងបញ្ជីនេះ នឹងត្រូវដាក់បញ្ចូលទៅក្នុងបញ្ជី IL នៅពេលវេលាជាក់លាក់ណាមួយ។

**៣. បញ្ជីអនុគ្រោះទូទៅ (General Exception List ឬ GEL):** បញ្ជីនេះសម្រាប់ផលិតផលទាំងឡាយណាដែលស្ថិតនៅក្រៅកិច្ចព្រមព្រៀង ពីព្រោះទំនិញទាំងនេះអាចបង្កគ្រោះថ្នាក់ដល់សុខភាពសាធារណៈ សន្តិសុខជាតិ ឬក៏សម្បត្តិវប្បធម៌របស់ប្រទេសនីមួយៗ។ មិនមានគម្រោងកាត់បន្ថយពន្ធគយលើទំនិញក្នុងបញ្ជីនេះទេ។ ប្រទេសជាសមាជិកអាស៊ានខ្លះ បានដាក់ចូលថ្នាំជក់ ភេសជ្ជៈមានជាតិអាល់កុល គ្រឿងបន្លាស់រថយន្ត និងផលិតផលប្រេងទៅក្នុងបញ្ជីនេះ ប៉ុន្តែបញ្ជី GEL នេះកំពុងស្ថិតនៅក្នុងដំណើរការត្រួតពិនិត្យឡើងវិញនៅឡើយ។

**៤. បញ្ជីអនុគ្រោះបណ្តោះអាសន្ន (Temporary Exception List ឬ TEL):** បញ្ជីនេះកើតឡើងចេញពីបញ្ជី IL និង SL។ នៅលើបញ្ជីនេះ គឺជាទំនិញដែលនឹងត្រូវផ្ទេរពីបញ្ជី SL ទៅក្នុងបញ្ជី IL បន្ទាប់ពីពេលវេលាសម្របសម្រួលបានអនុញ្ញាតឲ្យប្រទេសនីមួយៗ ។

### ខ. សហគមន៍សេដ្ឋកិច្ចអាស៊ាន (AEC)

ផែនការអាស៊ាន (ASEAN blueprint) ត្រូវបានអនុម័តឡើងក្នុងខែកញ្ញា ២០០៧។ ផែនការនេះគឺជាផែនទីបង្ហាញផ្លូវ ដើម្បីជម្រុញឲ្យសមាជិកអាស៊ានធ្វើការរៀបចំខ្លួនបង្កើតសមហាគមន៍

[19] ហង់ ជួនណារ៉ុន, សេដ្ឋកិច្ចនៃប្រទេសកម្ពុជា: មាគ៌ាទៅរកអនាគតដ៏ភ្លឺស្វាង-វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត, (ភ្នំពេញ, ២០១៤), ៥០០ ។

សេដ្ឋកិច្ចអាស៊ាន (ASEAN Economic Community ត្រឹមថ្ងៃទី ៣១ ធ្នូ ២០១៥ ។ សហគមន៍នេះត្រូវបានបង្កើតឡើងដោយឈរលើសសរស្តម្ភ៤ គឺ[20]

១. ជាទីផ្សារ និងមូលដ្ឋានផលិតរួម

២. តំបន់សេដ្ឋកិច្ចប្រកួតប្រជែង

៣. ការអភិវឌ្ឍសេដ្ឋកិច្ចប្រកបដោយសមធម៌

៤. សមាហរណកម្មអាស៊ានទៅក្នុងសេដ្ឋកិច្ចពិភពលោក

ក្នុងគោលដៅពង្រឹងនូវសសរស្តម្ភទាំង ៤ នេះបាន អាស៊ាននឹងឈានទៅសម្រេចនូវសមិទ្ធផលគន្លឹះចំនួន ៨ នៅចុងឆ្នាំ ២០១៥ ដែលជាឆ្នាំនៃការបង្កើតសហគមន៍សេដ្ឋកិច្ចអាស៊ានដែលមានដូចជា៖ [21]

**១. ពង្រីកទីផ្សារសេរីឲ្យកាន់តែធំ:** ពន្ធគយ និង ការរឹតបន្តឹងលើវិស័យសេវាកម្មនៅក្នុងអាស៊ានត្រូវបានលុបបំបាត់ជាបណ្តើរៗ ។

**២. កាត់បន្ថយថ្លៃដើមពាណិជ្ជកម្ម:** ធ្វើឲ្យកាន់តែងាយស្រួលចំពោះនីតិវិធីពាណិជ្ជកម្មឆ្លងប្រទេស ដែលរួមបញ្ចូលទាំងនីតិវិធីគយ វិធាននៃប្រភពដើម និង បទបញ្ញត្តិបច្ចេកទេសជាដើម ។

**៣. របបវិនិយោគកាន់តែប្រសើរឡើង:** ធ្វើឲ្យអាស៊ានក្លាយជាទិសដៅវិនិយោគដ៏ទាក់ទាញមួយ ដែលស្មើភាពចំពោះវិនិយោគិនក្នុងស្រុក និងអន្តរជាតិ។

**៤. លើកកម្ពស់បម្លាស់ទីកម្លាំងពលកម្មជំនាញ:** សម្របសម្រួលដល់ចលនាឆ្លងដែនធ្វើការរបស់កម្លាំងពលកម្ម និងអ្នកជំនាញ។

**៥. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី និងភាពជាដៃគូសេដ្ឋកិច្ចទូលំទូលាយ:** អាស៊ានផ្តល់ជូនអ្នកធ្វើធុរកិច្ច នូវឱកាសកាន់តែច្រើនដើម្បីពង្រីកវិសាលភាពរបស់ពួកគេ ទៅទីផ្សារខាងក្រៅ និងពង្រឹងសមត្ថភាពរបស់ពួកគេក្នុងតំបន់ និងពិភពលោក។

**៦. បរិយាកាសគាំទ្រវិស័យធុរកិច្ច និងនវកម្ម:** វាអាចសម្រេចបានតាមរយៈការអនុម័តក្របខ័ណ្ឌស្តង់ដាររួម, កិច្ចសហប្រតិបត្តិការ, គោលនយោបាយប្រកួតប្រជែង, ច្បាប់កម្មសិទ្ធិបញ្ញា, ច្បាប់ការពារអតិថិជន, និងគោលនយោបាយអភិវឌ្ឍន៍សហគ្រាសធនតូចនិងមធ្យមជាដើម។

---

[20] The ASEAN Secretariat, *ASEAN Integration Report 2015 [របាយការណ៍សមាហរណកម្មអាស៊ាន ២០១៥]*, (Jakarta: The AEAN secretariat, 2015), xvii.

[21] The ASEAN Secretariat, *Factsheet - ASEAN Economic Community [សហគមន៍សេដ្ឋកិច្ចអាស៊ាន]*, (Jakarta: The AEAN secretariat, 2015), xvii.

**៧. ការកែលម្អហេដ្ឋារចនាសម្ព័ន្ធរូបវន្ត:** វារួមបញ្ចូលទាំងប្រព័ន្ធដឹកជញ្ជូនឆ្លងប្រទេសដែលអាចចូលរួមកាត់បន្ថយថ្លៃដើមក្នុងការធ្វើជំនួញ និង ផ្តល់ឱកាសដល់ប្រជាពលរដ្ឋឆ្លងដែនធ្វើការជាមួយគ្នា ដែលនាំឲ្យផលិតភាពមានការកើនឡើង។

**៨. កាត់បន្ថយគម្លាតនៃការអភិវឌ្ឍន៍:** ស្របជាមួយនឹងដំណើរការសមាហរណកម្មក្នុងតំបន់កិច្ចផ្តួចផ្តើមដែលសំដៅកាត់បន្ថយគម្លាតនៃការអភិវឌ្ឍរវាងបណ្តាប្រទេសជាសមាជិកអាស៊ាន ក៏ត្រូវបានផ្តល់អាទិភាពផងដែរ។

## ២.៣ សេរីភាវូបនីយកម្មពាណិជ្ជកម្ម

### ២.៣.១ ការកែសម្រួលរបាំងពន្ធគយ

ដើម្បីរួមចំណែកដល់ការប្រកួតប្រជែងរបស់ប្រទេសកម្ពុជា ក្នុងកិច្ចសម្រួល និងពង្រឹងកិច្ចប្រតិបត្តិការពាណិជ្ជកម្មអន្តរជាតិ ប្រទេសកម្ពុជា បាននិងកំពុងអនុវត្តវិធានការក្នុងការសម្របសម្រួលពាណិជ្ជកម្ម តាមរយៈការធ្វើកំណែទម្រង់របាំងពន្ធគយ ដោយអនុលោមតាម កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី FTA ជាច្រើនរបស់កម្ពុជា ជាមួយនឹងប្រទេសជាដៃគូ។

#### ក. កិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា (FTA)

យោងតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញរបស់អាស៊ាន (ATIGA) ព្រះរាជាណាចក្រកម្ពុជា បានចាប់អនុវត្តកម្មវិធីកាត់បន្ថយអត្រាពន្ធគយតាំងពីឆ្នាំ ២០០៩ និងបានដាក់ចេញនូវកម្មវិធីមួយសម្រាប់ដំណាក់កាលបន្ទាប់រហូតដល់ឆ្នាំ ២០១៥ ដូចខាងក្រោម៖

- ពន្ធនាំចូលយ៉ាងតិច ៨០% នៃបន្ទាត់ពន្ធគយសរុបត្រូវស្មើ ឬតិចជាង ៥% ត្រឹមថ្ងៃទី ០១ខែមករា ឆ្នាំ ២០០៩
- ពន្ធនាំចូលលើផលិតផល ICT ត្រូវលុបទាំងស្រុងនៅថ្ងៃទី ០១ ខែមករា ឆ្នាំ ២០១០
- ពន្ធនាំចូលលើផលិផលកសិកម្មមិនទាន់កែច្នៃ នៅក្នុងបញ្ជីទំនិញរវេទយិត SL ត្រូវបានកាត់បន្ថយ ឬលុបមកសូន្យ ឬប្រាំភាគរយ (0-៥%) ត្រឹមឆ្នាំ ២០១៧
- ពន្ធនាំចូលលើផលិតផលកសិកម្មមិនទាន់កែច្នៃ នៅក្នុងបញ្ជីទំនិញរវេទយិតខ្ពស់ HSL ត្រូវអនុវត្តតាមអត្រា MFN
- ពន្ធនាំចូលលើផ្នែកសមារណកម្មអាទិភាព (Priority Integration Sector: PIS) ត្រូវលុបមក 0% នៅឆ្នាំ ២០១២។

ក្រៅពីនេះ កម្ពុជាក៏បានចូលរួមក្នុងកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីផ្សេងៗទៀត ក្នុងគោលបំណង លើកកម្ពស់កិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោកតាមរយៈការធ្វើសេរីកម្មពន្ធនាំចូល តាមកម្មវិធីដូចខាងក្រោម៖[22]

- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញសេរីរបស់អាស៊ាន-ចិន ACFTA
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញសេរីរបស់អាស៊ាន-កូរ៉េ AKFTA
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញសេរីរបស់អាស៊ាន-ជប៉ុន AJCEP
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញសេរីរបស់អាស៊ាន-អូស្ត្រាលី-ណូវែលហ្សេឡង់ AANZFTA
- កិច្ចព្រមព្រៀងពាណិជ្ជកម្មទំនិញសេរីរបស់អាស៊ាន-ឥណ្ឌា AIFTA

* សូមមើលឧបសម្ព័ន្ធទី ៣ អំពីប្រព័ន្ធអនុគ្រោះពន្ធគយផ្អែកទៅតាមកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរីនានា

### ខ. ពន្ធគយរបស់កម្ពុជាតាមប្រព្រឹត្តកម្មធម្មតា

នៅថ្ងៃទី ២៥ ឧសភា ២០០១ រាជរដ្ឋាភិបាលកម្ពុជាបានកាត់បន្ថយចង្កោមពន្ធគយពី ១២ មកនៅ ៤ ដែលមានអត្រាខ្ពស់បំផុតធ្លាក់ពី ១២០ភាគរយ មកត្រឹម ៣៥ភាគរយ។

**តារាងទី ២.៥ ៖ ប្រភេទពន្ធ និងអាករសម្រួលដោយគយ ២០១៥**

| ល.រ | ប្រភេទពន្ធ និងអាករ | អត្រាពន្ធ |
|---|---|---|
| ក. នាំចូល | | |
| ១ | ពន្ធគយ | 0% ; ៧% ; ១៥% ; ៣៥% |
| ២ | អាករពិសេស | 0% ; ៤,៣៥% ; ៥% ; ១0% ; ១៥% ; ២៥% ; ៣0% ; ៤៥% ; ៥0% |
| ៣ | អាករបន្ថែម | 0,0២$/លីត្រ លើប្រេងសាំង ; 0,0៤$/លីត្រ ចំពោះប្រេងម៉ាស៊ូត |
| ៤ | អាករលើតម្លៃបន្ថែម | ១0% |
| ii នាំចេញ | | |
| ១ | អាករនាំចេញ | 0% ; ៥% ; ១0% ; ១៥% ; ២0% ; ៥0% |

**ប្រភព:** *តារាងពន្ធគយឆ្នាំ ២០១២ បោះពុម្ពលើកទី ៣ ខែមករា ឆ្នាំ ២០១៥*

[22] អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា, *យុទ្ធសាស្ត្រ និងកម្មវិធីការងារកំណែទម្រង់និងទំនើបកម្មរបស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ២០១៤-២០១៨ (ភ្នំពេញ, ២០១៥) ២៤-៣១ ។*

ចង្កោមពន្ធ ៣៥ភាគរយនេះ ជួយការពារដល់ទំនិញប្រើប្រាស់ និងទំនិញពាក់កណ្តាលសម្រេចរបស់កម្ពុជាដូចជា ផលិតផលសាច់កែច្នៃ វាយនភ័ណ្ឌ និងសម្លៀកបំពាក់ជាដើម។ អត្រាពន្ធគយនៅកម្ពុជាត្រូវបាន កែសម្រួលជាបន្តបន្ទាប់ ក្នុងគោលដៅជម្រុញសេរីភាវូបនីយកម្មក្នុងវិស័យពាណិជ្ជកម្ម សំដៅជួញជម្រុញសេដ្ឋកិច្ចជាតិ។ *សូមមើលឧបសម្ព័ន្ធទី ៤ ប្រកាសអំពីការកែសម្រួលអត្រាពន្ធគយលើទំនិញនាំចូលមួយចំនួន។

អត្រាពន្ធគយរួមទាប ធ្វើឲ្យអ្នកវិនិយោគអាចទទួលបានធនធាន តាមតម្លៃប្រហាក់ប្រហែល ហើយកត្តានេះនាំឲ្យមានការធានាបានថាអ្នកផលិតសម្រាប់ផ្គត់ផ្គង់ទីផ្សារក្នុងស្រុករួមទាំង SMEs នឹងមិនទទួលរងគ្រោះដោយសារតែការនាំចូល ប៉ុន្តែផ្ទុយទៅវិញវាក៏ជួយជម្រុញឲ្យមានការអភិវឌ្ឍឧស្សាហកម្មប្រកួតប្រជែងលើការនាំចូល។

**តារាងទី ២.៦ ៖ ពន្ធគយសង្ខេបរបស់កម្ពុជា ២០០៩**

| អត្រាគោល | ចំនួនបន្ទាត់ពន្ធគយ | | | | សរុប |
|---|---|---|---|---|---|
| | ០ % | ៧% | ១៥% | ៣៥% | |
| សត្វ និងផលិតផលសត្វ | ២៧ | ៦ | ១៦៨ | ១២៥ | ៣៤៤ |
| ផលិតផលបន្លែ | ៣៤ | ១៩៦ | ១០៩ | ៥២ | ៣៩១ |
| ខ្លាញ់ និងប្រេង | ០ | ១៥០ | ០ | ០ | ១៥០ |
| អាហារវេចខ្ចប់ | ០ | ១១៦ | ៨៧ | ១៨៣ | ៣៨៦ |
| ផលិតផលរ៉ែ | ២១ | ៩២ | ៧១ | ១៣ | ១៩៧ |
| ផលិតផលគីមី ឬពាក់ព័ន្ធនិងឧស្សាហកម្ម | ១៥៣ | ៦៩៥ | ៧៦ | ១៧៤ | ១០៩៨ |
| ផ្លាស្ទិក | ៩៨ | ១៥៩ | ៦៧ | ៦៨ | ៣៩២ |
| ស្បែកសត្វ | ០ | ៤២ | ៥ | ៣៨ | ៨៥ |
| ឈើ និងផលិផលធ្វើពីឈើ | ០ | ៦៤ | ៥៣ | ១៩ | ១៣៦ |
| ក្រដាស និងប្រដាប់ធ្វើក្រដាស | ៩ | ២១១ | ០ | ៤ | ២២៤ |
| វាយនភណ្ឌ និងផលិតផលពាក់ព័ន្ធ | ០ | ៥៩៨ | ៨៦ | ២៤៣ | ៩២៧ |
| ស្បែកជើង | ០ | ២១ | ៣២ | ១០ | ៦៣ |
| ថ្ម/ស៊ីម៉ង់ត៍/សេរ៉ាម៉ិក | ០ | ១១៥ | ៥២ | ១៨ | ១៨៥ |
| ត្បូង | ១៣ | ៦២ | ០ | ០ | ៧៥ |
| សម្ភារៈធ្វើពីលោហៈធាតុ ឬលោហៈធាតុ | ១២៥ | ៤៧៤ | ១២៧ | ១០០ | ៨២៦ |

| | | | | | |
|---|---|---|---|---|---|
| គ្រឿងម៉ាស៊ីន និងបរិក្ខារអគ្គិសនី | ៣៨ | ១៥៩ | ១៣៤០ | ២៦៦ | ១៨០៣ |
| យានយន្ត | ៣៣ | ៨ | ៣១៩ | ៦៧ | ៤២៧ |
| ផ្នែកចក្ខុវេជ្ជសាស្រ្ត និងឧបករណ៍តន្ត្រី | ១៨ | ៥៣ | ២២១ | ៤៧ | ៣៣៩ |
| អាវុធ | ៦ | ០ | ០ | ២២ | ២៨ |
| ទំនិញឧស្សាហកម្មផ្សេងៗ | ៤៣ | ៤៥ | ៧៩ | ៤៩ | ២១២ |
| វត្ថុបុរាណ និងវត្ថុសិល្បៈ | ១០ | ០ | ០ | ០ | ១០ |
| បន្ទាត់ពន្ធគយសរុប | ៦២៨ | ៣២៦៦ | ២៩០៦ | ១៤៩៤ | ៨២៩៨ |
| ភាគរយនៃបន្ទាត់ពន្ធគយ | ៧.៥៧% | ៣៩.៣៣៦% | ៣៥.០៥% | ១៨.០៥% | ១០០% |

*ប្រភព៖ ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ២០១៣*

### ២.៣.២ ការកែសម្រួលរបាំងពាណិជ្ជកម្មមិនមែនពន្ធគយ

ប្រទេសកម្ពុជា មានច្បាប់ និងបទបញ្ញត្តិនានា ចំនួន ៥២ ដើម្បីធ្វើការដាក់កម្រិតលើលំហូរនៃទំនិញក្នុងវិស័យពាណិជ្ជកម្ម ដែលក្នុងនោះស្មើនឹង វិធានការមិនមែនពន្ធគយ (Non-Tariff Measures ឬ NTMs) សរុបចំនួន ២៤៣ ប្រភេទ។ វិធានការទាំងនោះត្រូវបានអនុម័តដោយក្រសួងស្ថាប័ននានា ចំនួន ១៤ មានដូចជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ, ក្រសួងសុខាភិបាល, ក្រសួងឧស្សាហកម្ម រ៉ែ និងថាមពល, ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ, ក្រសួងឧស្សាហកម្ម និងសិប្បកម្ម, ក្រសួងមហាផ្ទៃ, ក្រសួងពាណិជ្ជកម្ម, ក្រសួងបរិស្ថាន, គណៈកម្មាធិការជាតិជីវៈសុវត្ថិភាព, ធនាគារជាតិនៃកម្ពុជា, និងស្ថាប័ន ៣ ផ្សេងទៀត។[23]

ជាទូទៅ វិធានការនៃរបាំងមិនមែនពន្ធគយ (NTMs) ត្រូវបានគេបែងចែកជា ១៦ប្រភេទសំខាន់ៗ ប៉ុន្តែប្រភេទ NTMs ដែលត្រូវបានអនុម័តច្រើនបំផុតនៅកម្ពុជា គឺ ប្រភេទរបាំងបច្ចេកទេសពាណិជ្ជកម្ម (Technical Barriers to Trade ឬ TBT), វិធានការទាក់ទងនឹងការនាំចេញ (Export-related measures) និង វិធានការអនាម័យ និងភូតគាមអនាម័យ (Sanitary and Phytosanitary ឬ SPS) ។

[23] Economic Research Institute for ASEAN and United Nations Conference on Trade and Development, Non-tariff Measures in ASEAN [វិធានការមិនមែនពន្ធគយរបស់អាស៊ាន] , (Jakarta: National Library of Indonesia, 2016).

**តារាងទី ២.៧៖ ប្រភេទរបាំងមិនមែនពន្ធគយដែលប្រើប្រាស់នៅកម្ពុជា**

| កូដ | ប្រភេទរបាំងមិនមែនពន្ធគយ | ចំនួនវិធាន | ភាគរយ |
|---|---|---|---|
| A | វិធានអនាម័យ និងភូតគាមអនាម័យ (SPS) | ៣៦ | ១៤.៨ |
| B | របាំងបច្ចេកទេសពាណិជ្ជកម្ម | ១២១ | ៤៩.៨ |
| C | អធិការកិច្ចមុនពេលដឹកជញ្ជូន និងបែបបទផ្សេងៗ | ១ | ០.៤ |
| D | វិធានការការពារពាណិជ្ជកម្មបែបយថាភាព | ០ | ០ |
| E | វិធានការកំណត់បរិមាណ, អាជ្ញាប័ណ្ណ, កូតា, ការហាមឃាត់ | ៣ | ១.២ |
| F | វិធានការគ្រប់គ្រងថ្លៃ (រួមបញ្ចូលទាំងពន្ធបន្ថែម និងថ្លៃបន្ទុក) | ១២ | ៤.៩ |
| G | វិធានការហិរញ្ញវត្ថុ | ០ | ០ |
| H | វិធានការដែលប៉ះពាល់ដល់ការប្រកួតប្រជែង | ០ | ០ |
| I | វិធានាការវិនិយោគទាក់ទងនឹងពាណិជ្ជកម្ម | ០ | ០ |
| J | ការកំហិតការចែកចាយ | ០ | ០ |
| K | ការកំហិតចំពោះសេវាកម្មលក់ | ០ | ០ |
| L | ការឧបត្ថម្ភធន | ០ | ០ |
| M | ការរឹតបន្តឹងលទ្ធកម្មរដ្ឋាភិបាល | ០ | ០ |
| N | កម្មសិទ្ធបញ្ញា | ០ | ០ |
| O | វិធានប្រភពដើម | ០ | ០ |
| P | វិធានការទាក់ទងនឹងការនាំចេញ | ៧០ | ២៨.៨ |
| | សរុប | ២៤៣ | ១០០ |

ប្រភព: *Economic Research Institute for ASEAN, 2016*

### ២.៣.៣ ជំនួយសម្រាប់ពាណិជ្ជកម្ម

ជំនួយសម្រាប់ពាណិជ្ជកម្ម (Aids for Trade) ត្រូវបានផ្តួចផ្តើមជាសកលនៅឆ្នាំ ២០០៥ ដើម្បីពង្រឹងសមត្ថភាពនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ ឲ្យទទួលបានផលប្រយោជន៍កាន់តែល្អប្រសើរ ពីការចូលរួមប្រព័ន្ធពាណិជ្ជកម្មពិភពលោក ដើម្បីឈានទៅសម្រេចបាននូវការអភិវឌ្ឍប្រកបដោយចីរភាព និងការកាត់បន្ថយភាពក្រីក្រ។

ស្ថាប័នអន្តរជាតិមួយឈ្មោះថា Organization for Economic Cooperation and Development (OECD) ដើរតួនាទីយ៉ាងសំខាន់សម្រាប់ការផ្តល់ជំនួយពាណិជ្ជកម្ម (AfT)។ ក្នុងទិដ្ឋភាពផ្នែកហិរញ្ញវត្ថុ ជំនួយសម្រាប់ពាណិជ្ជកម្ម គឺសំដៅលើហិរញ្ញវត្ថុដែលជាផ្នែកមួយនៃជំនួយអភិវឌ្ឍន៍ផ្លូវការ Official Development Aids (ODA)។ ក្នុងឆ្នាំ ២០១៣ កម្ពុជាទទួលបាន ជំនួយ ODA ចំនួនប្រមាណ ៨៦២,២ លានដុល្លារ ដែលក្នុងនោះមាន ២៨៥,៧លានដុល្លារ ជាជំនួយសម្រាប់ពាណិជ្ជកម្ម (AfT)។

**ក្រាហ្វិកទី ២.៧៖ ជំនួយសម្រាប់ពាណិជ្ជកម្មមកកាន់កម្ពុជាឆ្នាំ ២០០៨ និង ២០១៣**




**ប្រភព:** *OECD, 2015*

** ទិន្នន័យលម្អិតនៃជំនួយសម្រាប់ពាណិជ្ជកម្មមកកាន់កម្ពុជា មានក្នុងឧបសម្ព័ន្ធទី ៥។*

គម្រោង និងជំនួយសម្រាប់ពាណិជ្ជកម្មសំដៅលើសកម្មភាពអាទិភាពទាំងឡាយណាដែលទាក់ទងនឹងវិស័យពាណិជ្ជកម្ម ដែលមាននៅក្នុងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរបស់ប្រទេសអ្នកស្នើសុំជំនួយ រួមមាន[24]៖

**១. ការងារបច្ចេកទេសពាណិជ្ជកម្ម:** ការរៀបចំយុទ្ធសាស្ត្រ និងគោលនយោបាយពាណិជ្ជកម្ម ការចរចារ និងការរៀបចំកិច្ចព្រមព្រៀងពាណិជ្ជកម្ម, ការងារអនុវត្តផែនការ និងពិនិត្យលទ្ធផល ។ល។

**២. ហេដ្ឋារចនាសម្ព័ន្ធពាណិជ្ជកម្ម:** ការកសាងផ្លូវថ្នល់ និងហេដ្ឋារចនាសម្ព័ន្ធដឹកជញ្ជូន ការកសាងបណ្តាញទូរគមនាគមន៍ដែលតភ្ជាប់ពីក្នុងស្រុក ទៅនឹងចរន្តសេដ្ឋកិច្ចពិភពលោក។ល។

[24] ម៉ម ម៉ានី, *អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម និងជំនួយសម្រាប់ពាណិជ្ជកម្ម*, (សិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់លើកទី៨, ខេត្តសៀមរាប, ១៧ មីនា ២០១៧)

**៣. ការកសាងសមត្ថភាពផលិតភាព:** ការគាំទ្រដល់វិស័យផលិតកម្មនានាដើម្បីមានលទ្ធភាពប្រកួតប្រជែង និងការធ្វើពិពិធកម្មទំនិញដើម្បីការនាំចេញទៅកាន់ទីផ្សារពិភពលោក ។ល។

**៤. ការកែតម្រូវវិធានពាណិជ្ជកម្ម:** ការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដូចជាការកាត់បន្ថយរបាំងពន្ធគយ និងស្ថានភាពពាណិជ្ជកម្មមិនល្អ ។ល។

**៥. តម្រូវការដែលទាក់ទងនឹងពាណិជ្ជកម្មផ្សេងៗទៀត**

## ២.៤ គោលនយោបាយជាតិលើវិស័យពាណិជ្ជកម្ម

### ២.៤.១ យុទ្ធសាស្ត្រចតុកោណ[25]

ក្នុងនីតិកាលទី ៤ កន្លងមក គោលដៅយុទ្ធសាស្ត្ររបស់រាជរដ្ឋាភិបាលកម្ពុជា គឺជាការបន្តធ្វើសមាហរណកម្មកម្ពុជាទៅក្នុងតំបន់ និងសហគមន៍អន្តរជាតិ ជាពិសេស តាមរយៈការចូលរួមក្នុងកិច្ចសហប្រតិបត្តិការក្នុងកម្រិតអនុតំបន់នានា ការកសាងសហគមន៍អាស៊ាន និងការបំពេញតួនាទីជាសមាជិកក្នុងអង្គការពិភពលោក និងអង្គការអន្តរជាតិផ្សេងទៀត។

**ក្រាហ្វិកទី ២.៨ ៖ យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី ៣**




**ប្រភព:** *រាជរដ្ឋាភិបាលកម្ពុជា, ២០១៣*

[25] រាជរដ្ឋាភិបាលកម្ពុជា, *យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣*, (២០១៣), ១៧-១៨ ។

ក្នុងគោលដៅនេះ រាជរដ្ឋាភិបាលសម្រេចបាននូវសមិទ្ធផលគួរឲ្យកត់សម្គាល់ ក្នុងការតភ្ជាប់ជាមួយនឹងបណ្តាប្រទេសក្នុងតំបន់ និងបានធ្វើឲ្យកាន់តែស៊ីជម្រៅនូវសេរីភាវូបនីយកម្មសេដ្ឋកិច្ច និងពាណិជ្ជកម្មតាមរយៈការកែទម្រង់យ៉ាងទូលំទូលាយលើក្របខណ្ឌគតិយុត្តិ ដែលបានធ្វើឲ្យកាន់តែប្រសើរនូវបរិយាកាសវិនិយោគ និងកិច្ចសម្រួលពាណិជ្ជកម្ម ព្រមទាំងបានលើកតម្កើងរបបពាណិជ្ជកម្មកម្ពុជា ឲ្យសមស្របជាមួយនឹងវិធាន និងបទដ្ឋាននអន្តជាតិ។

ក្នុងមុំទី ៤ នៃស្នូលចតុកោណនៃយុទ្ធសាស្ត្រចតុកោណ រាជរដ្ឋាភិបាលផ្តល់អាទិភាពលើៈ

ទី១ ការបំពេញតួនាទីរបស់ខ្លួនប្រកបដោយប្រសិទ្ធភព រាល់កិច្ចការតំបន់ និងអន្តរជាតិ។

ទី២ ការដាក់ចេញនូវគោលនយោបាយចាំបាច់នានា គួបផ្សំនឹងការផ្តោតលើការយកចិត្តទុកដាក់បណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ សម្រាប់ពលកម្មកម្ពុជាគ្រប់ស្រទាប់ ។

ទី៣ ការបន្តកែលម្អក្របខណ្ឌគតិយុត្ត សំដៅធ្វើឲ្យកាន់តែប្រសើរឡើងថែមទៀត នូវបរិស្ថានធុរកិច្ច ពាណិជ្ជកម្ម និងការវិនិយោគ។

ទី៤ ការចាត់វិធានពង្រឹង និងពង្រីកទីផ្សារនាំចេញរបស់កម្ពុជា ពិសេសតាមរយៈការចរចាបើកទីផ្សារជាមួយប្រទេសក្នុងតំបន់ និងក្រៅតំបន់ ការបន្តជម្រុញកែលម្អហេដ្ឋារចនាសម្ព័ន្ធ និងប្រព័ន្ធឡូជិស្ទីក រួមទាំងប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងគមនាគមន៍ ព្រមទាំងការកាត់បន្ថយរបាំងមិនមែនពន្ធនានា មានជាអាទិ៍ការកែលម្អស្តង់ដារ បទដ្ឋានអនាម័យ និងភូតគាមអាម័យ។

ទី៥ ការចាត់វិធានការគោលចាំបាច់នានា ដើម្បីចូលរួមក្នុងសហគមន៍អាស៊ានឆ្នាំ ២០១៥ ។

ទី៦ ការរៀបចំបង្កើតក្របខណ្ឌចាំបាច់នានា ដើម្បីគ្រប់គ្រងការប្រែប្រួលកើតចេញមកពីសហគមន៍អាស៊ានឆ្នាំ ២០១៥ ក្នុងគោលដៅធានាផលប្រយោជន៍របស់កម្ពុជា ជាពិសេសការគ្រប់គ្រងទីផ្សារពលកម្ម និងលំហូរពលករ។

### ២.៤.២ យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា

យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨ (CTIS 2014-2018) ឆ្លុះបញ្ចាំងពីការពិនិត្យឡើងវិញលើការវិវត្តសំខាន់ៗនៅក្នុងវិស័យពាណិជ្ជកម្ម និងធ្វើបច្ចុប្បន្នភាពយុទ្ធសាស្ត្រ និងទិសដៅរបស់កម្ពុជាសម្រាប់ សមាហរណកម្មពាណិជ្ជកម្ម ទៅក្នុងទីផ្សារសកល និងតំបន់។

យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ត្រូវបានណែនាំដោយគោលការណ៍បី[26] ៖

**ក. ធ្វើបច្ចុប្បន្នភាព និងពង្រឹងអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម**

CTIS 2014-2018 ពិនិត្យមើលកាលានុវត្តភាពថ្មីៗ និងបញ្ហាប្រឈមដែលបានកើតឡើងតាំងពីឆ្នាំ ២០០៧មក។ បន្ថែមពីលើនេះ CTIS 2014-2018 ផ្តល់នូវកាលានុវត្តភាពសម្រាប់ធ្វើបច្ចុប្បន្នភាពអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade SWAp) និងកំណត់ទិសដៅជាយុទ្ធសាស្ត្រសំខាន់ៗសម្រាប់វិស័យពាណិជ្ជកម្ម។

**ខ. ពង្រឹងសមត្ថភាពរាជរដ្ឋាភិបាលដើម្បីដឹកនាំ Trade SWAp**

ដំណើរការនៃការតាក់តែង CTIS 2014-2018 បានចាប់ផ្តើមជាមួយនឹងការកំណត់រកគោលដៅរឿងសំខាន់ៗ ដែលត្រូវដាក់បញ្ចូល និងកំណត់ទស្សនៈទាននានា ដែលត្រូវបានពិនិត្យឡើង និងអនុម័តដោយគណៈកម្មការអន្តរក្រសួង ដែលកត្តានេះបាននាំទៅរកជំហានមួយដើម្បីធានាថាលទ្ធផលការងារមានភាពម្ចាស់ពេញលេញ និងរួមគ្នា។

**គ. កំណត់រកបញ្ហាប្រឈម និងដាក់បញ្ចូលអាទិភាពថ្មីៗ**

CTIS 2014-2018 ទទួលស្គាល់ថាលក្ខខណ្ឌអាចមានការផ្លាស់ប្តូរ ហើយអាទិភាព និងតម្រូវការថ្មីអាចលេចចេញឡើង។ ដូច្នេះ CTIS 2014-2018 ក៏ធានាផងដែរថា អាទិភាពថ្មីជាគន្លឹះដែលកំណត់ដោយរដ្ឋាភិបាលត្រូវបានឆ្លុះបញ្ចាំងនៅក្នុងឯកសារថ្មី។ បញ្ហាប្រទាក់ក្រឡាថ្មីពីរត្រូវបានលើកឡើងក្នុង CTIS 2014-2018 ក្រោមសរសេស្តម្ភទីមួយ និងទីបី៖ (១) ភស្តុភារសម្រាប់ការដឹកជញ្ជូន និង (២) កង្វះខាតជំនាញសម្រាប់ការនាំចេញ។

### ២.៤.៣ អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្មកម្ពុជា

ដើម្បីដោះស្រាយបញ្ហាស្នូលនៃភាពប្រកួតប្រជែងវិស័យពាណិជ្ជកម្ម ការបង្កើតការងារ និងប្រាក់ចំណូល ព្រមទាំងការអភិវឌ្ឍមនុស្សជាតិប្រកបដោយនិរន្តរភាពក្នុងរយៈពេល ៥ឆ្នាំ ខាងមុខ ផែនទីបង្ហាញផ្លូវនៃអភិក្រមគ្របដណ្តប់លើវិស័យពាណិជ្ជកម្ម (Trade Sector-Wide Approach-Trade SWAP) នៅពេលបន្ទាប់របស់កម្ពុជា នឹងផ្តោតលើលទ្ធផលជាយុទ្ធសាស្ត្រចំនួន ២០។ លទ្ធផលទាំងនេះដោះស្រាយបញ្ហាប្រឈមជាក់លាក់ នៅកម្រិតលទ្ធភាពទីផ្សារ និងបរិយាកាសធុរកិច្ចនៅកម្រិតសង្វាក់តម្លៃនៅកម្រិតទីផ្សារការងារ និងជំនាញ ព្រមទាំងការគ្រប់គ្រង និង

[26] ក្រសួងពាណិជ្ជកម្ម, *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨* (ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម, ២០១៤), ១៣-១៤។

ប្រើប្រាស់ធនាធានជំនួយបច្ចេកទេស និងការផ្តោតលើវិស័យដែលត្រូវការកំណែទម្រង់ និងការអភិវឌ្ឍស្ថាប័ន។

វឌ្ឍនភាពធៀបនឹងលទ្ធផលជាយុទ្ធសាស្ត្រទាំង ២០ នេះ នឹងត្រូវវាស់វែងមួយផ្នែកដោយផលប៉ះពាល់នៃផលប្រយោជន៍របស់វាក្នុងការជួយដល់កម្ពុជា ដើម្បីសម្រេចគោលដៅអភិវឌ្ឍសេដ្ឋកិច្ចធំៗរបស់ខ្លួន ដូចជាគោលដៅពង្រឹងភាពប្រកួតប្រជែងវិស័យពាណិជ្ជកម្ម ការបង្កើតការងារថ្មីៗ និងកាន់តែល្អប្រសើរ ការបង្កើនប្រាក់ចំណូល និងការកាត់បន្ថយភាពក្រីក្រជាដើម។ ផលប៉ះពាល់ទូលំទូលាយទាំងនោះ មានចែងនៅក្រោមគោលដៅអភិវឌ្ឍន៍ចំនួន ៥។

**តារាងទី ២.៨ ៖ អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម**

| គោលដៅនៃការអភិវឌ្ឍ | |
|---|---|
| ១. ភាពប្រកួតប្រជែងត្រូវបានកែលម្អ រួមចំណែកកាត់បន្ថយភាពក្រីក្រតាមរយៈការបង្កើតការងារថ្មីៗ | |
| ២. កំណើនក្នុងការរួមចំណែករបស់វិស័យពាណិជ្ជកម្មដល់ GDP និងបង្កើនភាពចម្រុះនៃការនាំចេញ | |
| ៣. ពង្រឹងសមត្ថភាព RGC ដើម្បីរៀបចំនិងអនុវត្តគោលនយោបាយ និងយុទ្ធសាស្ត្រពាណិជ្ជកម្ម | |
| ៤. ភាពឆ្លើយតបរបស់ RGC ចំពោះតម្រូវការរបស់ផ្នែកឯកជន ជាលទ្ធផលនៃកិច្ចសន្ទនាកាន់តែប្រសើរ | |
| ៥. បង្កើនសមត្ថភាពរៀបចំផែនការអនុវត្ត ត្រួតពិនិត្យរបស់ RGC តាមរយៈ Trade SWAp | |
| សសរស្តម្ភទី១ ៖ កំណែទម្រង់ និង បញ្ហាអន្តរវិស័យ | |
| ១. កំណែទម្រង់គោលនយោបាយពាណិជ្ជកម្ម | ៤. ស្តង់ដារបច្ចេកទេស និងលក្ខខ័ណ្ឌ SPS |
| ២. កិច្ចសម្រួលពាណិជ្ជកម្ម | ៥. បរិយាសវិនិយោគសម្រាប់នាំចេញ |
| ៣. ការដឹកជញ្ជូនពាណិជ្ជកម្ម | ៦. កម្មសិទ្ធបញ្ញា |
| សសរស្តម្ភទី២ ៖ ការអភិវឌ្ឍផលិតផល និងសេវាកម្មសម្រាប់ការនាំចេញ | |
| ៧. សម្លៀកបំពាក់ ៨. ស្បែកជើង ៩. រោងចក្រផលិតធុនស្រាល ១០. អាហារកែច្នៃ ១១. អង្ករ | |
| ១២. ផលិតផលនេសាទ ១៣. ដំឡូងមី ១៤. កៅស៊ូ ១៥. ទេសចរណ៍ ១៦. ផលិតផលសូត្រ | |
| សសរស្តម្ភទី៣ ៖ ការបណ្តុះបណ្តាល និងធនធានមនុស្ស | |
| ១៧ ការលុបបំបាត់គម្លាក្នុងការនាំចេញ | ១៨ ការបញ្ជ្រាបពាណិជ្ជកម្ម |
| ១៩ ការពិនិត្យតាមដាន និងកៀងគរជំនួយសម្រាប់ពាណិជ្ជកម្ម | ២០ ការពង្រឹងការចូលរួមរបស់ផ្នែកឯកជន |

**ប្រភព:** *ក្រសួងពាណិជ្ជកម្ម, ២០១៤*

**២.៤.៤ ផែនការជាតិរយៈពេលមធ្យមសម្រាប់អនុវត្ត Trade SWAp**

គោលបំណងនៃផែនការជាតិរយៈពេលមធ្យម (Medium Term Plan ឬ MTP) គឺដើម្បីកំណត់អាទិភាពលើផ្នែកចាំបាច់មួយចំនួន ដើម្បីជម្រុញការអនុវត្តយុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មរបស់កម្ពុជា និងអភិក្រមគ្រប់ដណ្តប់លើវិស័យពាណិជ្ជកម្ម តាមរយៈការផ្តល់ជំនួយបច្ចេកទេស បន្ថែមពីលើការគាំទ្រដែលមានស្រាប់។

MTP ត្រូវបានបង្កើតឡើងតាមរយៈដំណើរការបួនចំណុចគឺ៖

១. ការវាយតម្លៃលើការលទ្ធផល និងសូចនាករនានា ដែលបានកំណត់ក្នុង ផែនទីបង្ហាញផ្លូវTrade SWAp និងធ្វើការចងក្រងជាឯកសារសម្រាប់តម្រូវការបច្ចេកទេសនាពេលអនាគត។

២. កំណត់អាទិភាពនៃសកម្មភាពចម្បងៗដើម្បីជម្រុញការអនុវត្ត ផែនទីបង្ហាញផ្លូវ Trade SWAp

៣. បង្កើតគោលការណ៍សំខាន់ៗចំនួន ៥ ដើម្បីក្រសួងពាណិជ្ជកម្ម និងអ្នកពាក់ព័ន្ធនានាបានចូលរួមក្នុងការបង្កើត និងគៀងគរធនធាន។

៤. បង្កើតគោលគំនិតថ្មីៗថែមទៀត សម្រាប់គ្រប់ដណ្តប់លើគោលការណ៍ទាំង ៥ ដែលបានបង្កើតឡើង។

ក្នុងនោះ MPT បានចែងពីគោល ការណ៍អទិភាពចំនួន ១០ អនុគណៈកម្មាធិការអភិវឌ្ឍន៍ពាណិជ្ជកម្ម និងការវិនិយោគពាក់ព័ន្ធនឹងពាណិជ្ជកម្ម ដែលមានដូចជា៖

១. កំណែទម្រង់គោលនយោបាយពាណិជ្ជកម្ម កំណែទម្រង់ច្បាប់ និងបទបញ្ញានានា

២. ជំនួយផ្នែកពាណិជ្ជកម្ម និងប្រព័ន្ធដឹកជញ្ជូន

៣. វិធានការភូតគាមនាម័យ និងប្រព័ន្ធគុណភាពផ្សេងទៀតក្នុងពាណិជ្ជកម្ម

៤. ការរៀបចំរចនាសម្ព័ន្ធវិស័យឯកជន

៥. ការបង្កើតខ្សែសង្វាក់តម្លៃរួមបញ្ចូលគ្នា

៦. ការបញ្រ្ជាបពាណិជ្ជកម្ម និងការគ្រប់គ្រងជំនួយសម្រាប់ពាណិជ្ជកម្ម

៧. ជំនាញសម្រាប់ការនាំចេញ

៨. បរិយាកាសវិនិយោគ សមាហរណកម្ម និងការតភ្ជាប់

៩. ការអភិវឌ្ឍជនបទដើម្បីជម្រុញការនាំចេញ

១០. លទ្ធភាពទទួលបានសេវាហិរញ្ញវត្ថុ

# ជំពូកទី ៣

# ការវិភាគទិន្នន័យ

## ៣.១ ការកំណត់អថេរ និងគំរូវិភាគ

គោលបំណងនៃការសិក្សានេះ គឺដើម្បីវិភាគពីឥទ្ធិពលនៃសេរីភាវូបនីយកម្មពាណិជ្ជកម្មមកលើកំណើនសេដ្ឋកិច្ចនៅប្រទេសកម្ពុជា។ ការសិក្សានេះប្រើប្រាស់វិធីសាស្ត្រ Log-Linear Regression ដែលអថេរទាំងអស់ត្រូវបានបំលែងជាលោកនេពែរ។

ការសិក្សានេះជ្រើសរើសយកអថេរពន្យល់ចំនួន៣ រួមមាន Trade openness, FDI, Gross Capital Formation ជាអថេរពន្យល់ និង GDP Growth Rate ជាអថេរអាស្រ័យដើម្បីសិក្សាពីឥទ្ធិពលនៃអថេរពន្យល់ទាំងបីមកលើអត្រាកំណើនផលិតផលក្នុងស្រុកសរុប (GDP Growth Rate) ដែលជាអថេរអាស្រ័យ។

ដូច្នេះយើងអាចកំណត់គំរូវិភាគ(Model) ដូចបានបង្ហាញខាងក្រោម៖ [27]

$$GDP = Ae^{\alpha t}$$

⇨ $$GDP = A.TOP^{\alpha}.FDI^{\beta}.GCF^{\gamma}.e^{ui}$$

ដើម្បីសិក្សាពីទំនាក់ទំនងនៃអថេរ TOP FDI និង GCF ទៅលើអថេរ GDP យើងត្រូវបំលែងសមីការខាងលើជាលោកនេពែរ នោះយើងបានសមីការ Log-Linear ដូចខាងក្រោម៖

$$LnGDP = LnA + \alpha Ln(TOP) + \beta Ln(FDI) + \gamma Ln(GCF)$$

ដែល GDP (GDP Growth Rate) : ជាបម្រែបម្រួលកំណើន GDP គិតជាភាគរយ

TOP (Trade Openness) : ជាការបើកចំហនៃពាណិជ្ជកម្ម គិតជាភាគរយនៃGDP

FDI (Foreign Direct Investment) : ជាវិនិយោគផ្ទាល់ពីបរទេស គិតជាភាគរយនៃGDP

GCF (Gross Capital Formation) : ជាចំណាយមូលធនដុល គិតជាភាគរយនៃGDP

[27] Adegboyega. S. B & Odusanya. I. A. Empirical Analysis of Trade Opennes, Capital Formation, FDI, and Economic Growth: Nigeria Experience. [ការវិភាគលើការបើកចំហពាណិជ្ជកម្ម ការចំណាយមូលធនដុល និងការវិនិយោគផ្ទាល់ពីបរទេស ជាមួយនឹងកំណើនសេដ្ឋកិច្ច: បទពិសោធន៍នីហ្សេរីយ៉ា]. *The International Journal of Social Sciences and Humanities Invention, 1*(1). (2014: 36-50).

## ៣.២ ការពន្យល់អត្ថន័យនៃអថេរវិភាគ

- GDP (GDP Growth Rate)

បម្រែប្រួលកំណើនផលិតផលក្នុងស្រុកសរុប (GDP) សំដៅដល់អត្រាកំណើននៃផលិតផល និងសេវាកម្មដែលប្រទេសមួយផលិតបានក្នុងរយៈពេលមួយជាក់លាក់។

- TOP (Trade Openness)

សំដៅដល់ការបើកចំហពាណិជ្ជកម្ម ឬសេរីភាវូបនីយកម្មពាណិជ្ជកម្ម មានន័យថាវាជាផលបូកនៃការនាំចេញនិងការនាំចូលទំនិញ និងសេវាកម្មធៀបនឹងផលិតផលសរុបក្នុងស្រុក (GDP)។ គេអាចគណនាបានដូចខាងក្រោម៖ [28]

$$Trade\ Openness = \frac{Export + Import}{GDP} \times 100$$

- FDI (Foreign Direct Investment)

ការវិនិយោគផ្ទាល់ពីបរទេស គឺជាលំហូរវិនិយោគសុទ្ធពីបរទេសនៅក្នុងសេដ្ឋកិច្ចនៃប្រទេសមួយ។ ក្នុងន័យនេះវារួមបញ្ចូលទាំងលំហូរមូលធនសុទ្ធពីវិនិយោគិនបរទេសដែលមកធ្វើការវិនិយោគក្នុងប្រទេសមួយធៀបនឹង GDP របស់ប្រទេសមួយនោះ។

- GCF (Gross Capital Formation)

ការចំណាយមូលធនដុល ដែលពីមុនធនាគារពិភពលោក (World Bank) ឲ្យឈ្មោះថាជាការវិនិយោគក្នុងស្រុកដុល (Gross Domestic Investment) សំដៅដល់ការវិនិយោគសាធារណៈលើទ្រព្យសកម្មថេររួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត អាគារ សាលារៀន មន្ទីរពេទ្យ។ល។

## ៣.៣ ការបង្ហាញទិន្នន័យ

តារាងខាងក្រោមនេះជាតារាងទិន្នន័យប្រើប្រាស់សម្រាប់ធ្វើការវិភាគ និងអនុវត្តគំរូវិភាគខាងលើ ដែលទិន្នន័យត្រូវបានដកស្រង់ចេញពីសន្ទស្សន៍ការអភិវឌ្ឍន៍ពិភពលោក (World Development Indicators) ចន្លោះពីឆ្នាំ១៩៩៤ ដល់ឆ្នាំ២០១៥។

[28] World Bank. *Trade (% of GDP). (2017).* http://data.worldbank.org/indicator/NE.TRD.GNFS.ZS?locations=KH (ថតចម្លងថ្ងៃទី ២ កក្កដា ២០១៧)

## តារាង៣.១៖ ទិន្នន័យសម្រាប់ធ្វើការវិភាគ

| Year | GDP | TOP | FDI | GCF |
|---|---|---|---|---|
| 1994 | 2.208 | 4.166 | 0.903 | 2.480 |
| 1995 | 1.863 | 4.354 | 1.478 | 2.678 |
| 1996 | 1.689 | 4.236 | 2.125 | 2.689 |
| 1997 | 1.726 | 4.369 | 1.778 | 2.709 |
| 1998 | 1.611 | 4.326 | 2.052 | 2.471 |
| 1999 | 2.477 | 4.545 | 1.888 | 2.832 |
| 2000 | 2.171 | 4.715 | 1.175 | 2.864 |
| 2001 | 2.084 | 4.735 | 1.303 | 2.927 |
| 2002 | 1.900 | 4.785 | 1.117 | 2.897 |
| 2003 | 2.141 | 4.813 | 0.560 | 3.001 |
| 2004 | 2.336 | 4.902 | 0.901 | 2.786 |
| 2005 | 2.584 | 4.919 | 1.791 | 2.916 |
| 2006 | 2.377 | 4.974 | 1.893 | 3.114 |
| 2007 | 2.324 | 4.932 | 2.306 | 3.054 |
| 2008 | 1.901 | 4.893 | 2.064 | 2.924 |
| 2009 | -2.442 | 4.655 | 1.592 | 3.062 |
| 2010 | 1.786 | 4.733 | 1.878 | 2.855 |
| 2011 | 1.956 | 4.733 | 1.825 | 2.839 |
| 2012 | 1.983 | 4.794 | 2.329 | 2.920 |
| 2013 | 2.012 | 4.853 | 2.164 | 2.982 |
| 2014 | 1.956 | 4.860 | 2.333 | 3.091 |
| 2015 | 1.951 | 4.851 | 2.243 | 3.111 |

**ប្រភព:** *World Bank, 2015 (Converted into Ln by SPSS program)*

## ៣.៤ ការបកស្រាយទិន្នន័យ

### ក. ការវិភាគលើលទ្ធផល

ដើម្បីបកស្រាយ និងអនុវត្តនូវសមីការខាងលើ អត្ថបទនេះប្រើប្រាស់ និងអនុវត្តកម្មវិធី SPSS ដើម្បីងាយស្រួលក្នុងការវិភាគលើលទ្ធផល។

**តារាង៣.២៖ តារាងទំនាក់ទំនង (ANOVA)**

| Variables | Coefficient | Std. Error | t-stat | P-value |
|---|---|---|---|---|
| Constant | -1.322 | 3.879 | -0.341 | .737 |
| TOP | 3.693 | 1.537 | 2.403 | .027 |
| FDI | .188 | .406 | 0.462 | .649 |
| GCF | -5.036 | 2.113 | -2.384 | .028 |
| R Square | .257 | | | |
| Adjusted R Square | .133 | | | |
| Std. Error of the Estimate | .923 | | | |
| F-statistics | 2.077 | | | |

*សម្គាល់៖ GDP is the Independent Variable; Calculated by SPSS program analysis.*

យោងទៅតាមតារាងខាងលើនេះ គេអាចសរសេរបាននូវសមីការដូចខាងក្រោម៖

$$GDP = 0.266.\ TOP^{3.693}\ FDI^{0.188}\ GCF^{-5.036}$$

P-value: (0.027) (0.649) (0.028)

### ខ. លទ្ធផលស្រាវជ្រាវ

**ការបើកចំហពាណិជ្ជកម្ម៖** យើងឃើញថាមេគុណនៃអថេរការបើកចំហពាណិជ្ជកម្ម (TOP) មានឥទ្ធិពលខ្លាំង មកលើកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ តាមការវិភាគទិន្នន័យខាងលើមេគុណនៃអថេរការបើកចំហពាណិជ្ជកម្ម (TOP) ស្មើនឹង៣.៦៩៣ មានន័យថា ប្រសិនបើការបើកចំហពាណិជ្ជកម្មកើន ១% នោះវាធ្វើឲ្យមានកំណើនផលិតផលក្នុងស្រុកសរុបប្រមាណ ៣.៦៩៣%។ ការរកឃើញឥទ្ធិពលវិជ្ជមានចំពោះការបើកចំហពាណិជ្ជកម្មលើកំណើនសេដ្ឋកិច្ច គឺស្របទៅតាមទ្រឹស្តី និងអត្ថបទស្រាវជ្រាវពីមុនមួយចំនួន (Shaheen, Ali, Kauser & Ahmed, 2013; Manni & Afzal, 2012; Hing, 2013) ដែលបានឆ្លុះបញ្ចាំងពីទំនាក់ទំនងវិជ្ជមាននៃអថេរទាំងពីរ។

**ការវិនិយោគផ្ទាល់ពីបរទេស៖** មេគុណនៃអថេរការវិនិយោគផ្ទាល់ពីបរទេស (FDI) មិនអាចធ្វើការពន្យល់ពីឥទ្ធិពលលើកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។ នេះអាចបណ្តាល មកពីភាពពុំសូវរឹងមាំនៃសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា។ កត្តាសំខាន់ៗមួយចំនួនដែលអាចជារបាំងរាំងស្ទះដល់ការទាក់ទាញវិនិយោគពីបរទេសមកកម្ពុជា គឺភាពខ្វះខាតនៃហេដ្ឋារចនាសម្ព័ន្ធរូបវន្ត ជាពិសេសចំពោះថ្លៃអគ្គិសនី។ បើតាមរបាយការណ៍របស់ធនាគារអភិវឌ្ឍន៍អាស៊ី (ADB) ឆ្នាំ២០១៦ បានបញ្ជាក់ថាការកើនឡើងយ៉ាងរហ័សនៃប្រាក់ឈ្នួលអប្បបរមា ការឡើងថ្លៃនៃប្រាក់ដុល្លារ និងភាពធុយស្រួយនៃឧស្សាហកម្មកាត់ដេរ ជាពិសេសការប្រកួតប្រជែងពីសំណាក់ប្រទេសមីយ៉ាន់ម៉ាដែលសម្បូរកម្លាំងពលកម្មនិងមានតម្លៃទាប បាននឹងកំពុងដាក់បន្ទុកដល់ភាពប្រកួតប្រជែងប្រទេសកម្ពុជា។ មួយវិញទៀត យោងតាមអង្គការតម្លាភាពអន្តរជាតិឆ្នាំ ២០១៥ កម្ពុជាមានសូចនាករអំពើពុករលួយខ្ពស់ជាងគេក្នុងអាស៊ាន ដោយជាប់ចំណាត់ថ្នាក់លេខ ១៥០ ក្នុងចំណោម ១៦៨ប្រទេស។ កត្តានេះហើយដែល ធនាគារពិភពលោកបានផ្តល់ចំណាត់ថ្នាក់ដល់កម្ពុជាលេខ ១២៧ ក្នុងចំណោម ១៨៩ប្រទេស ក្នុងរបាយការណ៍ការធ្វើធុរកិច្ចឆ្នាំ២០១៦ (Baker, 2016)។

**ការចំណាយមូលធនដុល៖** ផ្អែកតាមលទ្ធផលការវិភាគទិន្នន័យខាងលើមេគុណនៃអថេរការចំណាយមូលធនដុល (GCF) ស្មើនឹង -៥.០៣៦ មានសញ្ញាអវិជ្ជមាន មានន័យថាវាមានឥទ្ធិពលអវិជ្ជមានមកលើកំណើនសេដ្ឋកិច្ចរបស់ប្រទេសកម្ពុជា ពោលគឺរៀងរាល់ការកើនឡើងការចំណាយមូលធនដុល ១% នោះវាធ្វើឲ្យនោះវាធ្វើឲ្យផលិតផលក្នុងស្រុកសរុបមានការថយចុះ ៥.០៣៦%។ លទ្ធផលនេះស្របគ្នាទៅតាម Adhikary (2015) បញ្ជាក់ពីឥទ្ធិពលអវិជ្ជមានចំពោះការចំណាយមូលធនដុលលើកំណើនសេដ្ឋកិច្ចក្នុងរយៈពេលខ្លី។ មូលហេតុគឺរដ្ឋាភិបាលនៃបណ្តាប្រទេសកំពុងអភិវឌ្ឍន៍ដូចជាប្រទេសកម្ពុជាជាដើម ត្រូវការបង្កើនការវិនិយោគសាធារណៈលើទ្រព្យសកម្មថេរ រួមមានការសាងសង់ហេដ្ឋារចនាសម្ព័ន្ធរូបវន្ត សំណង់អាគារ សាលារៀនជាដើម ដើម្បីឆ្លើយតបទៅនឹងសកម្មភាពសេដ្ឋកិច្ច។ ដូច្នេះហើយ ការបង្កើនការចំណាយមូលធនដុលរបស់ រដ្ឋាភិបាលមានទំនាក់ទំនងអវិជ្ជមានជាមួយនឹងកំណើនសេដ្ឋកិច្ច ពីព្រោះផលត្រឡប់បានមកពីការវិនិយោគ (Return on investment) លើទ្រព្យសកម្មថេរទាំងនោះពុំអាចសម្រេចបានទេក្នុងរយៈពេលខ្លី។ ផ្ទុយទៅវិញក្នុងរយៈពេលវែង ការចំណាយមូលធនដុលនឹងមានឥទ្ធិពលវិជ្ជមានលើកំណើនសេដ្ឋកិច្ចនៃប្រទេសកម្ពុជា។

# សេចក្ដីសន្និដ្ឋាន និងអនុសាសន៍

## ១. សេចក្ដីសន្និដ្ឋាន

តាមការបកស្រាយលទ្ធផល ដោយប្រើគំរូវិភាគក្នុងសេដ្ឋកិច្ចមាត្រសាស្ត្រ (Econometrics) យើងឃើញថា ការធ្វើបើកចំហពាណិជ្ជកម្មពិតជានាំមកនូវសញ្ញាណវិជ្ជមានដល់សេដ្ឋកិច្ចកម្ពុជាប្រាកដមែន។ ការបើកចំហពាណិជ្ជកម្មនេះអាចធ្វើទៅបាន តាមរយៈការខិតខំបន្តពង្រឹងគោលនយោបាយសេរីភាវូបនីយកម្មពាណិជ្ជកម្ម ដែលអាចនាំកម្ពុជាឈានទៅធ្វើសមាហរណកម្ម សេដ្ឋកិច្ចរបស់ខ្លួនទៅក្នុងសេដ្ឋកិច្ចតំបន់ និងពិភពលោក។ យ៉ាងណាមិញ យើងមិនអាចផ្ដោតតែលើទ្រឹស្ដីក្នុងការវិភាគតែមួយមុខ ដើម្បីទាញសេចក្ដីសន្និដ្ឋាននោះទេ។ ជាក់ស្ដែង ក្នុងបរិបទសង្គមកម្ពុជាបច្ចុប្បន្ន យើងឃើញមានចំណុចអវិជ្ជមានមួយចំនួនដែលបណ្ដាល មកពីការអនុវត្តគោលនយោបាយសេរីភាវូបនីយកម្មពាណិជ្ជកម្មនេះផងដែរ។

ជាការឆ្លើយតប ទៅនឹងបញ្ហាដែលបានកើតឡើង ក្នុងន័យសំដៅបន្តលើកកម្ពស់ និងពង្រឹងកំណែទម្រង់វិស័យពាណិជ្ជកម្ម រាជរដ្ឋាភិបាលកម្ពុជាបានដាក់ចេញនូវគោលនយោបាយជាច្រើន ដើម្បីជាត្រីវិស័យក្នុងការឈានទៅរកប្រព័ន្ធពាណិជ្ជកម្មមួយដែលកាន់តែល្អប្រសើរ។ ទន្ទឹមនេះ យើងឃើញថា គោលនយោបាយដែលបានកំណត់ដោយរាជរដ្ឋាភិបាលមានលក្ខណៈជាប្រព័ន្ធប្រកបដោយចក្ខុវិស័យវែងឆ្ងាយ ប៉ុន្តែចំពោះការអនុវត្តនូវគោលនយោបាយទាំងនោះនៅមានកម្រិតនៅឡើយ។ នេះជាកត្តាមួយ ដែលធ្វើអោយមានការរាំងស្ទះដល់ដំណើរការសេរីភាវូបនីយកម្មពាណិជ្ជកម្ម និងបង្កជាផលលំបាកមួយចំនួនធំដល់រាជរដ្ឋាភិបាល និងប្រជាពលរដ្ឋកម្ពុជា។

មួយវិញទៀត តាមការវិភាគដោយប្រើប្រាស់សមីការ Log-linear regression អថេរនៃការវិនិយោគផ្ទាល់ពីបរទេស ពុំអាចធ្វើការពន្យល់ពីឥទ្ធិពលទៅលើកំណើនសេដ្ឋកិច្ចរបស់កម្ពុជាឡើយ។ កត្តានេះបណ្ដាលមកពី ភាពធុយស្រួយនៃ FDI របស់កម្ពុជា។ ជាក់ស្ដែង ហេដ្ឋារចនាសម្ព័ន្ធរូបវន្តរបស់កម្ពុជាពុំទាន់មានគ្រាប់គ្រាន់ ថ្លៃឈ្នួលពលកម្មអប្បបរមាបន្តកើនឡើងជាលំដាប់ ការកើនឡើងការប្រកួតប្រជែងពីសំណាក់ប្រទេសជិតខាងកាន់តែខ្លាំង និងបញ្ហាដ៏ទៃជាច្រើនទៀត បាននឹងកំពុងធ្វើអោយវិនិយោគិនបរទេសមួយចំនួនអាចរារែកចិត្ត ក្នុងការមកបណ្ដាក់ទុនវិនិយោគនៅកម្ពុជា។ ចំណែកអថេរនៃការចំណាយមូលធនដុល បានបង្ហាញសញ្ញាណអវិជ្ជមានដល់កំណើនសេដ្ឋកិច្ចកម្ពុជា។ យើងអាចសន្និដ្ឋានបានថា នេះជាការខាតបង់ក្នុងរយៈពេលខ្លីប៉ុណ្ណោះ ប៉ុន្តែជា

ការពិត ក្នុងរយៈពេលវែង ប្រទេសកម្ពុជានឹងទទួលបានផលប្រយោជន៍ត្រឡប់មកវិញ ពីការវិនិយោគលើទ្រព្យសកម្មទាំងនោះ ។

ជារួម បើទោះបីជាប្រទេសកម្ពុជា ទទួលបាននូវគុណប្រយោជន៍សេដ្ឋកិច្ចនៅមានកម្រិតពីការធ្វើសេរីភាវូបនីយកម្មពាណិជ្ជកម្មកន្លងមក ប្រទេសកម្ពុជាបាននឹងកំពុងធ្វើដំណើរលើមាគ៌ាមួយដ៏ត្រឹមត្រូវក្នុងការធ្វើទំនើបកម្មសេដ្ឋកិច្ច ដើម្បីលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋសំដៅបន្តរក្សាឲ្យកំណើនសេដ្ឋកិច្ចក្នុងកម្រិតខ្ពស់មួយ។ ក្រោមឥទ្ធិពលនៃសេរីភាវូបនីយកម្មបច្ចុប្បន្ន នៅពេលដែលប្រទេសកម្ពុជាកាន់តែបើកចំហទីផ្សាររបស់ខ្លួនទៅកាន់តំបន់ និងពិភពលោកតម្រូវអោយ ប្រទេសកម្ពុជាចាំបាច់ពង្រឹងភាពប្រកួតប្រជែងរបស់ខ្លួន និងជាពិសេសប្តូរឥរិយាបថរបស់ខ្លួនដោយផលិតទំនិញ និងសេវាកម្មសម្រាប់នាំចេញ ពីព្រោះក្នុងដំណើរការសេរីភាវូបនីយកម្មពាណិជ្ជកម្ម ប្រទេសកម្ពុជាអាចបន្តស្ថេរភាពកំណើនសេដ្ឋកិច្ចទៅបាន លុះត្រាតែមានសកម្មភាពដ៏ខ្លាំងក្លានៃការហូរចេញ និងហូរចូលទំនិញ និងសេវាកម្ម។

## ២. អនុសាសន៍

ដើម្បីធានាអោយកម្ពុជាអាចទទួលបាននូវផលប្រយោជន៍កាន់តែប្រសើរឡើង ពីសេរីភាវូបនីយកម្មពាណិជ្ជកម្ម រាជរដ្ឋាភិបាលកម្ពុជាគួរពិចារណាលើដំណោះស្រាយបញ្ហាមួយចំនួនៈ

- រដ្ឋាភិបាលគួរតែខិតខំរកវិធានការដោះស្រាយបញ្ហាឱនភាពជញ្ជីងពាណិជ្ជកម្ម។ ក្នុងន័យនេះ កម្ពុជាគួរតែធ្វើយ៉ាងណា ដើម្បីលើកកម្ពស់ការនាំចេញអោយបានកាន់តែច្រើន។ កម្ពុជាចាំបាច់ត្រូវតែជម្រុញពិពិធកម្មក្នុងការផលិត ពោលគឺត្រូវធ្វើទំនើបកម្ម និងឯកទេសកម្មទាំងវិស័យកសិកម្ម និងឧស្សាហកម្ម ដោយធ្វើការផលិត និងនាំចេញនូវផលិតផលទាំងឡាយណាដែលកម្ពុជាមានឧត្តមភាពស្រាប់ដូចជាស្រូវ កៅស៊ូ ជាដើម។
- រដ្ឋាភិបាលក៏ត្រូវពង្រឹងផងដែរនូវការអនុវត្តគោលនយោបាយគាំទ្រពាណិជ្ជកម្ម ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិអោយកាន់តែមានប្រសិទ្ធភាព តាមរយៈការរឹតបន្តឹងការអនុវត្តការងារដោយមានប្រព័ន្ធតាមដាន-ត្រួតពិនិត្យមួយ ដែលអាចធានាអោយមានតម្លាភាព និងធានាអោយបាននូវទីផ្សារទទួលទិញផលិតផលក្នុងតម្លៃសមរម្យមួយ ទាំងក្នុង និងក្រៅស្រុកសម្រាប់កសិករ។ បន្ថែមលើនេះ ការអភិវឌ្ឍមូលធនមនុស្ស គឺជាកត្តាចាំបាច់មួយ ក្នុងការជម្រុញអោយការអនុវត្តគោលនយោបាយជាតិគាំទ្រវិស័យពាណិជ្ជកម្មនេះកាន់តែមានប្រសិទ្ធភាព ។

- រាជរដ្ឋាភិបាលកម្ពុជាក៏ត្រូវយកចិត្តទុកដាក់ផងដែរ ក្នុងការកសាងបរិយាសកាសល្អមួយសម្រាប់ការវិនិយោគ និងការធ្វើពាណិជ្ជកម្មអន្តរជាតិ។ ប្រការនេះរួមបញ្ចូលទាំងការកែសម្រួលក្របខណ្ឌគតិយុត្តិ បែបបទរដ្ឋបាល ការកសាង និងពង្រឹងគុណភាពហេដ្ឋារចនាសម្ព័ន្ធ និងការផ្ដល់កិច្ចសម្របសម្រួលពាណិជ្ជកម្ម និងវិនិយោគជាដើម។

# ឯកសារពិគ្រោះ

## ឯកសារជាភាសាខ្មែរ


ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ. ២០១៥. *របាយការណ៍បូកសរុបកសិកម្ម រុក្ខាប្រមាញ់ និងនេសាទប្រចាំឆ្នាំ ២០១៤-២០១៥ និងទិសដៅការងារសម្រាប់ឆ្នាំ ២០១៥-២០១៦.* ភ្នំពេញ

ក្រសួងពាណិជ្ជកម្ម. ២០១៤. *យុទ្ធសាស្ត្រសមាហរណកម្មពាណិជ្ជកម្មកម្ពុជា ២០១៤-២០១៨* ,ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម។

ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ. ២០១៦. *របាយការណ៍តាមដានវឌ្ឍនភាពម៉ាក្រូសេដ្ឋកិច្ចកម្ពុជា: ការវាយតម្លៃពាក់កណ្តាលឆ្នាំ ២០១៦.* ភ្នំពេញ ។

ឃឹម ច័ន្ទតារា និង ផូ ស្រីស្រស់,*ការជំរុញការនាំចេញអង្ករកម្ពុជាឆ្នាំ ២០១៥ (សម្ព័ន្ធអ្នកផលិតស្រូវ និងនាំចេញអង្ករកម្ពុជា),* សារណាបញ្ចប់ការសិក្សា, (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនិតីសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៣), ១៣ ។

ចម ប្រសិទ្ធ. ២០០៤. *កម្ពុជា និងអង្គការពាណិជ្ជកម្មពិភពលោក* , ភ្នំពេញ៖ ក្រសួងពាណិជ្ជកម្ម។

ធនាគារជាតិនៃកម្ពុជា. ២០១៦. *របាយការណ៍ប្រចាំឆ្នាំ ២០១៦.* ភ្នំពេញ ។

ម៉ម ម៉ានី. ២០១៧. *អភិក្រមគ្របដណ្តប់វិស័យពាណិជ្ជកម្ម និងជំនួយសម្រាប់ពាណិជ្ជកម្ម*, សិក្ខាសាលាផ្សព្វផ្សាយថ្នាក់តំបន់លើកទី៤, ខេត្តសៀមរាប ១៧ មីនា ។

រាជរដ្ឋាភិបាលកម្ពុជា. ២០១៣. *យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣*។

វង្សី វិស្សុត. ២០១៧. កម្ពុជា: អតីតកាល បច្ចុប្បន្ន និងអនាគត*,* បទបង្ហាញនៅមជ្ឈមណ្ឌលសហប្រតិបត្តិការកម្ពុជា-កូរ៉េ, សាកលវិទ្យាល័យភូមិន្ទភ្នំពេញ, ០៣ កុម្ភៈ។

វិទ្យាស្ថានជាតិស្ថិតិ និងធនាគារជាតិនៃកម្ពុជា. ២០១៦. *របាយការណ៍អំពីវិនិយោគផ្ទាល់ពីបរទេសឆ្នាំ ២០១៤*, ភ្នំពេញ។

ស៊ុំ សុចិន្តា. ២០១៣. *ប្រវត្តិគំនិតសេដ្ឋកិច្ច*. ភ្នំពេញ៖ សាកលវិទ្យាល័យជាតិគ្រប់គ្រង

ហង់ ជួនណារ៉ុន. ២០១៤. *សេដ្ឋកិច្ចនៃប្រទេសកម្ពុជា: មាគ៌ាទៅរកអនាគតដ៏ភ្លឺស្វាង-វឌ្ឍនភាព បញ្ហាប្រឈម និងទស្សនវិស័យទៅអនាគត*, ភ្នំពេញ។

ហឿន រតនៈ និង គាន ចន្ទ្រាវត្តី,*ឥទ្ធិពលនៃកំណែទម្រង់របាំងពាណិជ្ជកម្មលើការនាំចេញ-នាំចូលរបស់ប្រទេសកម្ពុជា (១៩៩៧-២០១០),* សារណាបញ្ចប់ថ្នាក់បរិញ្ញាបត្រ, (ភ្នំពេញ៖ សាកលវិទ្យាល័យភូមិន្ទនិតីសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១២), ១០ ។

ឡុង ម៉ាមីឌី, *«សេដ្ឋកិច្ចអន្តរជាតិ»*, (មេរៀនសម្រាប់ថ្នាក់បរិញ្ញាប័ត្រឆ្នាំទី២, សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងវិទ្យាសាស្ត្រសេដ្ឋកិច្ច, ២០១៣) ។

អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា. ២០១៥. *យុទ្ធសាស្ត្រ និងកម្មវិធីការងារកំណែទម្រង់និងទំនើបកម្មរបស់ អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា ២០១៤-២០១៨, ភ្នំពេញ។*

## ឯកសារជាភាសាបរទេស

